# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*ឌុច ខ្ញុំសូមថ្លែងនៅចំពោះមុខលោកថា*
*លោកជាមនុស្សមិនទៀងត្រង់ ហើយលោកបានទម្លាក់កំហុសមកលើ*
***នួន ជា** ចំពោះឧក្រិដ្ឋកម្មដែលលោកផ្ទាល់បានប្រព្រឹត្តឡើង...*
*ដែលលោកគឺជាអ្នកទទួលខុសត្រូវដោយផ្ទាល់តែម្តង។*

***មេធាវី ម៉ៃខល ផេស្តមិន (មេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា)***

## ជំពូកទី ១ ៖ ទិដ្ឋភាពទូទៅ

សប្តាហ៍នេះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** បានបន្តចូលខ្លួនមកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សី ក្រោមការសួរដេញដោលដោយសហព្រះរាជអាជ្ញា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ និងក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **នួន ជា** ។ សហព្រះរាជអាជ្ញាបានបញ្ចប់ការសាកសួរដេញដោលរបស់ខ្លួននៅថ្ងៃច័ន្ទ (វគ្គទី១) មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានប្រើប្រាស់ពេលវេលាបន្ទាប់សួរដេញដោល **ឌុច** ក្នុងគោលបំណងគាំទ្រដល់សហព្រះរាជអាជ្ញា ដែលមានពេលវេលារហូតដល់ថ្ងៃអង្គារ (វគ្គទី១)។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានជីកកកាយពីការជាប់ពាក់ព័ន្ធរបស់ជនជាប់ចោទ **អៀង សារី** អំពីការចាប់ខ្លួនក្រុមបញ្ញាជន និង អំពីការប្រព្រឹត្តជាក់លាក់ទៅលើជនរងគ្រោះមួយចំនួន។

លោកចៅក្រម **ហ្សង់ ម៉ាកឡាវែន៍** និងប្រធានអង្គជំនុំជម្រះ **និល ណុន** បានចោទសួរសំណួរមួយចំនួនដល់សាក្សី **ឌុច** មុននឹងផ្តល់ឱកាសដល់ក្រុមមេធាវីការពារក្តីជនជាប់ចោទ **នួន ជា** ធ្វើការសួរដេញដោលសាក្សី។ គោលបំណងនៃការសួរដេញដោលរបស់មេធាវីការពារក្តី គឺដើម្បីបង្ហាញពីភាពមន្ទិលសង្ស័យចំពោះភាពគួរឲ្យជឿជាក់លើសាក្សី **ឌុច** ។ សាក្សីបានបដិសេធមិនឆ្លើយតបសំណួរមួយចំនួន ដែលចោទសួរដោយមេធាវី **ម៉ៃខល ផេស្តមិន** និងបានលើកឡើងជាច្រើនលើកថា គាត់សុំប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយដាក់ពិរុទ្ធលើខ្លួនឯង ចំពោះសំណួរទាំងឡាយដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍មុនរបបកម្ពុជាប្រជាធិបតេយ្យ។

បញ្ហាជាច្រើនបានកើតឡើងនៅក្នុងពេលផ្តល់សក្ខីកម្មរបស់សាក្សី **ឌុច** បានញាំងឲ្យមានការប្រកែក

តតាំងគ្នាជាហូរហែនៅក្នុងបន្ទប់សវនាការ ស្តីអំពីនីតិវិធីនៃការដាក់បង្ហាញឯកសារចំពោះមុខសាក្សី ដែលឯកសារទាំងនោះត្រូវចាត់ទុកថា ជាឯកសារបានដាក់ជូនអង្គជំនុំជម្រះ។ យោងតាមសេចក្តីប្រកាសរបស់អង្គជំនុំជម្រះ នាសប្តាហ៍បន្ទាប់ ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** និង **ខៀវ សំផន** នឹងធ្វើការសួរដេញដោលសាក្សី **ឌុច** ដែលក្រុមនីមួយៗមានរយៈពេលមួយថ្ងៃ។

## ជំពូកទី២ ៖ សក្ខីកម្មសង្ខេប

អង្គជំនុំជម្រះ និងភាគីទាំងឡាយបានបញ្ចប់ការសួរដេញដោលសាក្សី **ឌុច** លើអង្គហេតុពាក់ព័ន្ធនឹងរចនាសម្ព័ន្ធទំនាក់ទំនងរបស់ថ្នាក់លើជាមួយមន្ទីរសន្តិសុខស-២១ និងអង្គហេតុទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ ក្នុងការកម្ទេចខ្មាំងដែលបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថាជាសត្រូវ រួមមាន ៖ ក្រុមបញ្ញាជន ជនជាតិវៀតណាម (ហៅថា យួន) ព្រមទាំងចារកម្ម *ស៊ី.អាយ.អេ* និង *កា.ហ្សេ.បេ*។

### ក. ការបញ្ចប់ការសួរដេញដោលសាក្សី ឌុច ដោយសហព្រះរាជអាជ្ញា

សហព្រះរាជអាជ្ញា បានប្រើប្រាស់ពេលវេលាបន្ថែម ១ម៉ោង[1] ដែលទទួលបានពីការចែករំលែកពីក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ព្រះរាជអាជ្ញា **វីល្លៀម ស្មីត** បានផ្តោតលើរបាយការណ៍ស្តីពីការចូលរួមរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅក្នុងកិច្ចប្រជុំ (អង្គមេទ្និញ) ដែល **ឌុច** មានវត្តមាន។ សាក្សីបានបញ្ជាក់ថា គាត់ពិតជាបានចូលរួមនៅក្នុងកិច្ចប្រជុំទាំងនោះនៅចន្លោះ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៦ និង ឆ្នាំ១៩៧៨។ **ឌុច** បានថ្លែងថា គាត់បានឃើញ **ប៉ុល ពត** និង **នួន ជា** មានវត្តមាននៅលើវេទិកាសម្រាប់ថ្នាក់អធិបតី ប៉ុន្តែគាត់មិនចងចាំ ថាតើ **ខៀវ សំផន** និង **អៀង សារី** បានចូលរួមក្នុងកិច្ចប្រជុំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ ទេ ព្រោះមានថ្នាក់ដឹកនាំជាច្រើនបានចូលរួមនៅពេលនោះ។

បន្ទាប់មក ព្រះរាជអាជ្ញា **ស្មីត** បានចោទសួរពីគោលគំនិត ស្តីពី *"ទំនាស់ផ្ទៃក្នុងនៅក្នុងសង្គមកម្ពុជា"* ដែលបានកំណត់នៅក្នុងមហាសន្និបាតបក្សដំបូង ដែលបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី *ទង់បដិវត្តន៍*។ **ឌុច** បានបញ្ជាក់ថា គាត់បានអាន "ខចែង" ស្តីពីការបែងចែកវណ្ណៈសង្គម ដូចតទៅ ៖ វណ្ណៈកម្មករ វណ្ណៈកសិករ វណ្ណៈអនុធន វណ្ណៈនាយទុន និង វណ្ណៈសក្តិភូមិ ។ សាក្សីក៏បានរាយរាប់ពីទំនាស់ផ្សេងទៀត ដែលបានកំណត់នៅក្នុងទស្សនាវដ្តី *ទង់បដិវត្តន៍*រួមមានដូចជា ៖ ទំនាស់កម្មករជាមួយនាយទុន ទំនាស់អនុធនជាមួយនាយទុន ទំនាស់រវាងកសិករជាមួយនាយទុន និង កសិករជាមួយម្ចាស់ដី។ សាក្សី **ឌុច** បានថ្លែងថា ពាក្យថា "ទំនាស់" គឺមានពន្យល់នៅក្នុងទស្សនវិជ្ជា (បដិចសមុប្បាត)។ សាក្សីក៏បានបរិយាយពីទំនាស់មួយទៀត គឺ *"ទំនាស់រវាងយើង និងខ្មាំង ជាទំនាស់ស្លាប់រស់ បានន័យថា បើមួយនៅរស់ ត្រូវតែអត់មានមួយទៀត"*។ **ឌុច** បានបន្តផ្តល់សក្ខីកម្មថា បក្សកុម្មុយនីស្តកម្ពុជាបានរកឃើញថា កសិករមានភាគរយខ្ពស់បំផុតនៃប្រជាជនទូទាំងប្រទេស (៨៥%) និងត្រូវបានគេចាត់ទុកថា ទទួលរងការជិះជាន់ច្រើនជាងគេបំផុតពីវណ្ណៈផ្សេងៗនៅក្នុងសង្គមកម្ពុជាជំនាន់នោះ ជាពិសេស ពីវណ្ណៈម្ចាស់ដី។ ហេតុនេះ បានជាបក្សកំណត់ចរិតលក្ខណៈនៃទំនាស់រវាងកសិករនិងម្ចាស់ដីថា ជាទំនាស់ម្ខាងស្លាប់ ម្ខាងរស់ ឬហៅថា ទំនាស់បដិបក្ខ។[2]

### *ក.១. ថ្នាក់ដឹកនាំនៃការិយាល័យគណៈមជ្ឈិម ៖ ខៀវ សំផន និង សឿ វ៉ាស៊ី ហៅ "ឌឿន"*

សហព្រះរាជអាជ្ញា បានស្នើសុំឲ្យមានការបញ្ជាក់ចម្លើយរបស់សាក្សី **ឌុច** ដែលបានផ្តល់សក្ខីកម្មនាសប្តាហ៍កន្លងមកទាក់ទងនឹងការិយាល័យគណៈមជ្ឈិម និងតួនាទីរបស់ **ខៀវ សំផន** នៅក្នុងការិយាល័យនេះប្រៀបធៀបនឹងតួនាទីរបស់កម្មាភិបាល **ឌឿន**។ កន្លងមក **ឌុច** បានជម្រាតុលាការថា ការិយាល័យគណៈមជ្ឈិម គឺសំដៅទៅលើ " ការិយាល័យ ៨៧០" ។[3] ប៉ុន្តែសប្តាហ៍នេះ នៅពេលមានការចោទសួរ ថាតើការិយាល័យគណៈមជ្ឈិម និងការិយាល័យ ៨៧០ គឺជាការិយាល័យតែមួយ? **ឌុច** បែរជាបញ្ជាក់ថា " ការិយាល័យនេះជាកន្លែងធ្វើការជាប្រចាំ" របស់ថ្នាក់ដឹកនាំ ៥រូប ក្នុងចំណោម ៧រូប នៅ " គណៈអចិន្ត្រៃយ៍" រួមមាន ៖ **ប៉ុល ពត**, **នួន ជា**, **អៀង សារី** (ហៅក្រៅថា " បងវ៉ាន់" ) **វ៉ន វ៉េត** និង **សុន សេន** ។[4] តាមការបកស្រាយនេះហាក់បង្ហាញឲ្យឃើញថា ការិយាល័យ ៨៧០ គឺមិនសំដៅទៅលើអង្គភាពដែលស្ថិតក្នុងរចនាសម្ព័ន្ធរដ្ឋបាលរបស់បក្សកុម្មុនីស្តកម្ពុជាមិនដូចជាការិយាល័យគណៈមជ្ឈិមឡើយ ប៉ុន្តែជាទីតាំងរបស់ថ្នាក់ដឹកនាំធ្វើការងាររបស់ពួកគេ។

ត្រឡប់មកពិភាក្សាអំពីមុខតំណែង និងការទទួលខុសត្រូវរបស់ **ខៀវ សំផន** និង កម្មាភិបាល **ឌឿន** (មុនបញ្ជូន **ឌឿន** ទៅក្រសួងពាណិជ្ជកម្ម)។ កាលពីសប្តាហ៍មុន សាក្សីបានថ្លែងថា បុគ្គលទាំងពីររូបនេះមានតួនាទីជាប្រធានការិយាល័យគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។[5] ភាពមិនដូចគ្នាគឺនៅត្រង់ថា ខណៈដែល **ខៀវ សំផន** មានតួនាទីជាអ្នកត្រួតពិនិត្យលើអង្គភាពមួយចំនួន ដូចជា ស្ថានីយ៍ថាមពលនៅចាក់អង្រែ[6] ជាដើម ចំណែកឯ **ឌឿន** មានតួនាទីគ្រាន់តែជាអ្នករៀបចំឯកសារ។[7] សប្តាហ៍នេះ **ឌុច** បានរម្លឹកឡើងវិញថា **ខៀវ សំផន** មានភារៈជាអ្នកត្រួតពិនិត្យអង្គភាពមួយចំនួន មិនត្រឹមតែមន្ទីរ ៨៧០ និងប្រដូចជនជាប់ចោទថាជាសមាជិកពេញសិទ្ធិនៃ " គណៈមជ្ឈិម" ។ ចំណែកឯកម្មាភិបាល **ឌឿន** វិញ គឺមិនទទួលបានឋានៈដូច **ខៀវ សំផន** ទេ ព្រោះគាត់គ្រាន់តែជាសមាជិកត្រៀម។ យោងតាមសាក្សី **ឌុច** បានឲ្យដឹងថា *"គ្មានអ្នកណាអាចទៅ ធ្វើអីឲ្យរង្គើបង **ខៀវ សំផន** បានទេ"*។ លើសពីនេះ សាក្សីបានសន្និដ្ឋានថា កម្មាភិបាល **ឌឿន** មិនត្រឹមតែមាន អាយុតិចជាង **ខៀវ សំផន** ទេ និង *"ក្លាយជាសមាជិកពេញសិទ្ធិរបស់បក្សក៏ដោយ ក៏គាត់មិនមានឥទ្ធិពលដូចបង **ខៀវ សំផន** ព្រោះថាបង **ខៀវ សំផន** ក្តាប់នយោបាយបានច្រើនជាង និងច្បាស់ជាង"*។[8] សាក្សីបន្តថា **ខៀវ សំផន** បានទទួលតំណែងជាប្រធានការិយាល័យ ៨៧០ បន្ទាប់ពីកម្មាភិបាល **ឌឿន** ត្រូវបានគេបញ្ជូនទៅក្រសួងពាណិជ្ជកម្ម[9] ព័ត៌មានក្រោយមក គាត់ត្រូវបានគេចាប់ខ្លួន និងកម្ទេច។ ទោះជាយ៉ាងណាសក្ខីកម្មរបស់សាក្សី **ឌុច** នៅតែមិនទាន់ច្បាស់ ថាតើបុគ្គលទាំងពីររូបនេះ **ខៀវ សំផន** និង កម្មាភិបាល **ឌឿន** មានងារជាប្រធានការិយាល័យគណៈមជ្ឈិមក្នុងពេលតែមួយ ឬក៏ពួកគាត់ទាំងពីរកាន់តំណែងនៅពេលផ្សេងគ្នា? ប៉ុន្តែយោងតាមឋានៈរបស់ **ខៀវ សំផន** ត្រូវបានគេសន្មតថា មានអំណាចជាងក្នុងការចាត់ចែងការងារទូទៅ។ វាក៏នៅតែជាការស្រពិចស្រពិលថាតើ **ខៀវ សំផន** បានទទួលតំណែងបន្ត (ស្នង) ពីកម្មាភិបាល **ឌឿន** (ដែលជាប្រធានមួយរូប) បន្ទាប់ពីមានការផ្ទេររូបគាត់ចេញ និងក្រោយមកត្រូវចាប់ខ្លួន។ **ឌុច** ក៏មិនបានដឹងថាតើនរណាជាអ្នកទទួលបំពេញភារកិច្ចរបស់កម្មាភិបាល **ឌឿន** នៅការិយាល័យមជ្ឈិម បន្ទាប់ពីគាត់ផ្ទេរទៅក្រសួងពាណិជ្ជកម្ម។

### *ក.២. គោលនយោបាយប្រឆាំងមន្ត្រីនៃរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា*

សាក្សី **ឌុច** បានបញ្ជាក់ថា មានគោលនយោបាយប្រឆាំងនឹងមន្ត្រីរដ្ឋាភិបាលបង្រួបបង្រួមជាតិ ជាពិសេស ចំពោះអ្នកទាំងឡាយដែលមិនមែនជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា។ មន្ត្រីទាំងនោះ បូករួមទាំងមន្ត្រីការទូត និងឯកអគ្គរាជទូត ដែលបានចាត់តាំងដោយរដ្ឋាភិបាលបង្រួបបង្រួមជាតិ។ ដំបូងឡើយ អ្នកទាំងនោះបញ្ជូនទៅមណ្ឌលអប់រំកែប្រែ (បឹងត្របែក ឬប្រាំងចម្រេះ) ដោយគណៈមជ្ឈិមរកឃើញថា ពួកគេទាំងនោះ គឺមាន *"សមាសភាពមិនល្អ"* បន្ទាប់មកបញ្ជូនទៅមន្ទីរស-២១។ សាក្សី **ឌុច** បានរៀបរាប់ថា *"សមាសភាពមិនល្អរឿងអីខ្លះ វាហួសពីការយល់ដឹងរបស់ខ្ញុំ ហើយខ្ញុំមិនដឹងជាក់ស្តែងពីបញ្ហាអស់នេះទេ ឲ្យតែគេបញ្ជូនមកត្រូវតែសួរ"*។ សាក្សីបានបន្តថា លោក **ហួត សម្បត្តិ** ដែលជាឯកអគ្គរដ្ឋទូតនៃប្រទេសយូហ្គោស្លាវី និងរូម៉ានី ហើយក៏ជាប្រតិភូតំណាងរបស់កម្ពុជានៅអង្គការសហប្រជាជាតិ[10] ក៏ត្រូវបានបញ្ជូនទៅមន្ទីរស-២១ដែរ។

### *ក.៣. ឯកសារមន្ទីរស-២១*

យោងតាមសាក្សីបានឲ្យដឹងថា គាត់គោរពបទបញ្ជារបស់ជនជាប់ចោទ **នួន ជា** ដែលបានសម្រេចឲ្យកម្ទេចអ្នកទោសប្រមាណជាង ៥០០នាក់ ដែលនៅសេសសល់ក្នុងគុកទួលស្លែង មុនពេលដែលកងទ័ពវៀតណាមបានចូលមកដល់នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ទោះបីជាយ៉ាងណា **នួន ជា** មិនបានណែនាំគាត់ឲ្យធ្វើយ៉ាងណាចំពោះឯកសារមន្ទីរស-២១ទេ។ **ឌុច** បានរម្លឹកថា ក្រោយមកប្រហែលជាឆ្នាំ១៩៩៣ ឬឆ្នាំ១៩៩៤ គាត់ និង **នួន ជា** បានជួបគ្នានៅស្រុកសំឡូត ខេត្តបាត់ដំបង។ នៅពេលនោះ គាត់បានប្រាប់ទៅអតីតមេគាត់ថា គាត់មិនបានចាត់ការ ឬធ្វើការបំផ្លាញឯកសារមន្ទីរស-២១ចោលទេ (**នួន ជា** សួរនាំគាត់អំពីឯកសារនោះ: *"រួចចុះ ឯកសារ មិត្ត?"*)។ សាក្សីបានទទួលស្គាល់ថា ទោះបីជាគាត់មិនចងចាំសម្តីគ្រប់ម៉ាត់ដែល **នួន ជា** ស្តីបន្ទោសគាត់ក៏ដោយ ក៏អ្វីដែលគាត់នៅចាំ គឺ **នួន ជា** បាននិយាយថា៖ *"មិត្តអន់ណាស់ គ្រាន់តែសភាពការណ៍ប៉ុណ្ណឹងក៏ក្តាប់មិនបាន"* បន្ទាប់មក **នួន ជា** បានប្រាប់គាត់ថា *"នែ៎ ខាងខ្ញុំ កម្ទេចខ្មោចអស់ហើយ"*។ **ឌុច** ក៏បានរៀបរាប់បន្ថែមពីអារម្មណ៍របស់ **នួន ជា** តាមការយល់ឃើញថា *"តាមខ្ញុំធ្លាប់ដឹងនៅពេលធ្វើការចុះឡើងជាមួយនឹង **បងនួន** អារម្មណ៍របស់គាត់តែប៉ុណ្ណឹង មិនសូវទទួលស្គាល់ចំណុចខ្សោយរបស់ខ្លួនទេ ច្រើនតែសង្គ្រប់អ្នកខាងក្រោម ឲ្យតែអ្នកខាងក្រោមមានចំណុចខ្វះខាត"*។

ក្រោយមក នៅពេលមានសំណួរ ថាតើអ្វីដែលគាត់ (សាក្សី) បាននិយាយរ៉ាយរ៉ាប់ជូនតុលាការរយៈពេលប្រាំមួយថ្ងៃនេះ គឺជាសក្ខីកម្មពិតប្រាកដឬយ៉ាងណា? **ឌុច** បានឆ្លើយតបថា ៖

> *ខ្ញុំបាននិយាយកាលពីថ្ងៃមុនៗ ថាខ្ញុំបានប្រកាន់ខ្ជាប់គោលជំហរទាំងអម្បាលមានដែលខ្ញុំបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និង អ្វីគ្រប់យ៉ាងដែលខ្ញុំបាននិយាយក្នុងអំឡុងពេលជំនុំជម្រះក្តីនៃសំណុំរឿង០០១។ ពេលខ្លះ ក៏ខ្ញុំនិយាយក្នុងបរិបទជាគោលការណ៍... ពេលខ្លះខ្ញុំបានចូលទៅដល់ព័ត៌មានលម្អិត អំពីអ្វីដែលខ្ញុំបានឮ និងតាមការយល់ដឹងរបស់ខ្ញុំ។*

## ខ. សក្ខីកម្មសង្ខេបរបស់ ឌុច ដែលសួរដេញដោលដោយក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

មេធាវី **ហុង គឹមសួន** ដែលជាមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានផ្តោតសំខាន់ទៅលើសំណួរដែលពាក់ព័ន្ធនឹងការចោទប្រកាន់ចំពោះការចូលរួមរបស់ **អៀង សារី** នៅក្នុងការចាប់ខ្លួន និងសម្លាប់បុគ្គលិកនៃក្រសួងការបរទេស ព្រមទាំងបញ្ញវន្តជាច្រើន។ លើសពីនេះ លោកមេធាវីក៏បានសួរសំណួរមួយចំនួន ផ្តោតសំខាន់ទៅលើជនរងគ្រោះនៅមន្ទីរស-២១ រួមមាន ៖ លោក **ចៅ សេង** លោក **អ៊ុក កេត** និងលោក **រស់ សារិន** ថាតើ **អៀង សារី** ធ្លាប់បាន ឬក៏បានដឹងឮ និងបានចាត់វិធានការរារាំង ឬទប់ស្កាត់ការចាប់ខ្លួន និងសម្លាប់បុគ្គលទាំងនោះដែរឬទេ? ការជជីកដេញដោលលើអង្គហេតុទាំងនេះ គឺក្នុងគោលបំណងបង្ហាញពីការតវ៉ាទាមទាររបស់កូនក្តីខ្លួន (ដើមបណ្តឹងរដ្ឋប្បវេណី) ប្រឆាំងនឹងជនជាប់ចោទ។

ចំណែកឯ មេធាវី **លីម៉ា ង្វៀន** ដែលជាមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីវិញ បានផ្តោតសំខាន់ទៅលើរចនាសម្ព័ន្ធទំនាក់ទំនង និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ជាពិសេសការចេញបទបញ្ជា និង ការដាក់សម្ពាធពីថ្នាក់លើចំពោះការកំណត់អត្តសញ្ញាណ ឬ ស៊ើបរកក្រុមចារកម្មដើម្បីចាប់ខ្លួន និងសួរចម្លើយ។

### *ខ.១. ជនជាប់ចោទ អៀង សារី និងការចាប់ខ្លួនក្រុមបញ្ញវន្ត*

សាក្សី **ឌុច** បានបញ្ជាក់ថា មន្ត្រីធ្វើមាតុភូមិនិវត្តន៍ពីក្រសួងការបរទេស រួមមាន ឯកអគ្គរដ្ឋទូតដែលបានបំពេញការងារនៅក្រៅប្រទេស និងក្រុមបញ្ញវន្តត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១។ សាក្សីចងចាំឈ្មោះមួយចំនួន ដូចជា លោក **មាឃ ទូច** លោក **ហេង សុខឃាង** លោក **ចៅ សេង** និង លោក **វ៉ាន់ ពីនី**។ អ្នកទាំងនេះត្រូវបានគេកម្ទេចទាំងអស់។ សាក្សីបានបន្តថា *"រឿងសម្រេចចាប់ខ្លួន គឺពិតជាខាងមជ្ឈិមជាអ្នកសម្រេច នេះបើនិយាយឲ្យទូលាយ។ ក៏ប៉ុន្តែ បើនិយាយឲ្យចំ គឺ* ***បងប៉ុល*** *ជាអ្នកសម្រេច។ នៅក្នុងករណីខ្លះ* ***បងនួន*** *ជាអ្នកសម្រេច"* ។ **ឌុច** បានឆ្លើយក្នុងន័យវិជ្ជមានចំពោះសំណួរដែលថា ប្រធានអង្គភាពប្រចាំភូមិភាគបូព៌ាមានឥទ្ធិពលនៅក្នុងការចាប់ខ្លួនមនុស្សត្រឹមកម្រិតណា (ឧទាហរណ៍ ប្រធានអង្គភាពអាចនឹងបដិសេធមិនគោរពតាមបទបញ្ជា ឬអាចធ្វើការស្នើសុំកុំឲ្យដកបុគ្គលណាមួយ)។

ចំពោះសិទ្ធិអំណាចក្នុងនាមជាប្រធានអង្គភាពមួយ មេធាវី **ហុង គឹមសួន** បានចោទសួរ **ឌុច** ថា កាលពីគាត់នៅទទួលខុសត្រូវនៅមន្ទីរស-២១ តើគាត់ធ្លាប់បានឆ្លើយឆ្លង ឬទំនាក់ទំនងជាមួយនឹង **អៀង សារី** ដែរឬទេ? **ឌុច** បានបញ្ជាក់ថា *"បើនិយាយពីលិខិតទាក់ទងរបស់* ***អៀង សារី*** *មកមន្ទីរស-២១ គឺគ្មានទេ"* និងបញ្ជាក់ថា គាត់ធ្លាប់ឃើញ **អៀង សារី** តែពីចម្ងាយចំនួនពីរដង។ ទោះបីជាយ៉ាងណា **ឌុច** បានពន្យល់ថា *"តាមគោលការណ៍ មុននឹងមានការចាប់ខ្លួនមនុស្សនៅក្រសួងការបរទេស សេចក្តីសម្រេចពី* ***អៀង សារី*** *គឺជាការចាំបាច់"* ។ **ឌុច** ជឿជាក់ថា ចំណាត់ការនេះអាចធ្វើទៅបានតម្រូវឲ្យមានការព្រមព្រៀងពីក្រសួងការបរទេសជាមុន មុននឹងធ្វើការចាប់ខ្លួនមនុស្ស ហើយបញ្ជូនទៅមន្ទីរស-២១ *"ជាពិសេស ការអនុវត្តទៅលើ* ***អ៊ុក កេត****"* ។[11] សាក្សី **ឌុច** បានបន្តជម្រាបប្រាប់តុលាការថា គាត់បានដឹងរឿងរបស់លោក **អ៊ុក កេត** តាមរយៈសំណុំរឿង០០១ ព្រោះថា ភរិយា និងកូនស្រីរបស់ជនរងគ្រោះរូបនេះ គឺជាដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០១។ សាក្សីបានថ្លែងបន្ថែមថា លោក **អ៊ុក កេត** ត្រូវបានបញ្ជូនទៅមន្ទីរស-២១ នៅមុនពេលគាត់មានភារៈជាលេខាធិការ ដូច្នេះ សាក្សីសន្និដ្ឋានថា លោក **អ៊ុក កេត** គឺជាអ្នកការទូតរបស់រដ្ឋាភិបាល

បង្រួបបង្រួមជាតិកម្ពុជា។ **ឌុច** បានធ្វើការសន្និដ្ឋានដូចគ្នា នៅពេលមានសំណួរពីមេធាវី **ហុង គឹមសួន** ពាក់ព័ន្ធនឹងជនរងគ្រោះ **រស់ សារិន**។[12]

យោងតាម **ឌុច** ការចាប់ខ្លួនលោក **ចៅ សេង** ដែលជាមនុស្សពោរពេញទៅដោយប្រជាប្រិយភាព និងជាបុគ្គលដែលសាក្សីគោរពសរសើរ ព្រោះគាត់បានធ្វើការតស៊ូប្រឆាំងនឹងរបប **លន់ នល់** និងក៏ជាបុគ្គលដែលបានបង្កើតវិទ្យាស្ថានគរុកោសល្យសម្រាប់បណ្តុះបណ្តាលសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ។ សាក្សីបានឱ្យដឹងថា លោក **ចៅ សេង** បានធ្វើការនៅក្រសួងការបរទេស និងបានចាប់ខ្លួនក្រោមឈ្មោះផ្សេង (ឈ្មោះមួយទៀត) ខណៈពេលនោះ **អៀង សារី** មិនមានវត្តមាននៅក្រសួងការបរទេសទេ ហើយក៏មិនដឹងពីការចាប់ខ្លួន **ចៅ សេង** ដែរ។

### *ខ.២. ខ្មាំងបដិវត្តន៍*

ការប្រឈមនឹងអត្ថបទដកស្រង់ចេញពី *ទង់បដិវត្តន៍* ដែលថា តើកម្លាំងអ្វីដែលប្រឆាំងនឹងបដិវត្តន៍របស់ខ្មែរក្រហម? **ឌុច** បានអះអាងថា លេខាធិការបក្សកុម្មុយនីស្តបានកំណត់ថា *"សត្រូវស្លាប់រស់"* របស់បក្សកុម្មុយនីស្តកម្ពុជា គឺ *"យួន"* ភ្នាក់ងារ *ស៊ី.អាយ.អេ* និង ភ្នាក់ងារ *កា.ហ្សេ.ប៊េ* ការកំណត់បែបនេះ គឺដើម្បីកម្ទេចសត្រូវទាំងនោះ។ សាក្សីបានពន្យល់បន្ថែមថា *"ស៊ី.អាយ.អេ"* នៅក្នុងសម័យនោះ គឺសំដៅដល់ខ្មែរនៅក្នុងប្រទេសខ្មែរដែលទទួលការចាត់តាំងពីភ្នាក់ងាររបស់សហរដ្ឋអាមេរិក។ ចំណែកឯ *"យួន"* វិញ គឺសំដៅលើជនជាតិវៀតណាមដែលនៅក្នុងទឹកដីខ្មែរ ឬក៏សំដៅទៅលើខ្មែរដែលមាន *"និន្នាការ"* យួន ឬ ហៅឲ្យចំអតីតកងកម្លាំងរបស់ *"បក្សប្រជាជនបដិវត្តន៍កម្ពុជា"*។

### *ខ.៣. មុខងារមន្ទីរសន្តិសុខ ស-២១*

**ឌុច** បានថ្លែងថា គ្រប់សមាជិកបក្សទាំងអស់ សុទ្ធតែទទួលបានការបណ្តុះបណ្តាលយ៉ាងល្អ ដើម្បីអាចរកឃើញភ្នាក់ងារចារកម្មទាំងនោះ។ សាក្សីបានរម្លឹកថា *"ភារកិច្ចរបស់មន្ទីរស-២១ គេហៅថា ជាអង្គភាពអនុវត្តភារកិច្ចប្រតិចារកម្ម ឬ កងគ្រោះស្បូណាល់"* ពោលគឺ រកឲ្យឃើញភ្នាក់ងារ *ស៊ី.អាយ.អេ* ភ្នាក់ងារ *កា.ហ្សេ.ប៊េ* និងចារកម្មយួនលេបទឹកដី។ គោលដៅចុងក្រោយរបស់មន្ត្រីមន្ទីរស-២១ គឺធ្វើយ៉ាងណាទាញយកចម្លើយសារភាពពីអ្នកទោស។ **ឌុច** បានឲ្យដឹងថា គាត់មិនបានពិនិត្យពិច័យមើលលើភាពត្រឹមត្រូវនៃចម្លើយសារភាពដែលទទួលបានពីមន្ទីរស-២១ទេក្នុងពេលដែលគាត់ទទួលខុសត្រូវ ប៉ុន្តែគាត់បានរៀបចំចងក្រង និងផ្ញើឯកសារទាំងនោះទៅគណៈអចិន្ត្រៃយ៍ ដើម្បីធ្វើការសម្រេចចិត្ត។ **ឌុច** បានជម្រាបអង្គជំនុំជម្រះថា វាហាក់ដូចជាមានសម្ពាធយ៉ាងខ្លាំងពី **សុន សេន** នៅពេលដែលពួកគាត់មិនអាចរកឃើញភ្នាក់ងារចារកម្ម។ នៅពេលដែល **នួន ជា** បានចុះមកត្រួតពិនិត្យមន្ទីរស-២១ គាត់តែងតែណែនាំពួកយើងឲ្យអនុវត្តតាមគោលនយោបាយបក្ស។

***ការប្រើប្រាស់ចម្លើយសារភាព*** ៖ យោងតាម **ឌុច** បានឲ្យដឹងថា គណៈអចិន្ត្រៃយ៍ជាអ្នកធ្វើសេចក្តីសម្រេចថាតើនឹងត្រូវចាត់ការដូចម្តេចចំពោះអ្នកទោសដែលបានឆ្លើយសារភាព។ ចុងក្រោយបំផុត អ្នកទោសទាំងនោះនឹងត្រូវកម្ទេចចោលនៅមន្ទីរស-២១ ឬជើងឯក (ដែលគេហៅថា វាលពិឃាដ)។ **ឌុច** បានផ្តល់សក្ខីកម្មថា **នួន ជា** បានណែនាំគាត់ឲ្យថតរូបអ្នកទោសដែលត្រូវបានគេសម្លាប់ ដើម្បីជាភស្តុតាងបញ្ជាក់ថា ពួកគេពិតជាត្រូវបានសម្លាប់ពិតប្រាកដមែន។ ចម្លើយសារភាពមួយចំនួនត្រូវបានផ្សព្វផ្សាយដល់មហាជនស្តាប់

ដែលនេះជាផ្នែកមួយនៃការឃោសនារបស់បក្ស មានដូចជា ចម្លើយសារភាពរបស់លោក **ពេជ ធន** ហៅ "**សោម**" ឈ្មោះ **ប៉ង់** ជាប្រធានមន្ទីរពេទ្យ៩៨ លោក **ម៉ែន សាន** ហៅ "**យ៉ា**" និង **គុយ ធួន** ។

***ការរើសអើងប្រឆាំងនឹងជនជាតិវៀតណាម និង ជនជាតិភាគតិចចាម ៖*** **ឌុច** បានថ្លែងថា ការរើសអើងប្រឆាំងនឹងជនជាតិវៀតណាម និង ជនជាតិភាគតិចចាម បានចាប់ផ្តើមបន្ទាប់ពីការរំដោះនៅថ្ងៃទី១៧ មេសា ១៩៧៥។ សាក្សីបានរម្លឹកថា **ប៉ុល ពត** បានបញ្ជាឲ្យបញ្ចេញប្រជាជនវៀតណាមទាំងអស់ចេញពីទឹកដីកម្ពុជា។ ទោះជាយ៉ាងនេះក្តី មិនមានការប្រកាសតាមវិទ្យុពីផែនការជម្លៀស ហើយសាក្សីក៏មិនបានដឹងពីចំនួនប្រជាជនវៀតណាមដែលត្រូវបានគេបញ្ជូនចេញពីប្រទេសកម្ពុជាដែរ។ យោងតាមសាក្សី នៅថ្ងៃទី៨ មករា ១៩៧៨ **នួន ជា** បានណែនាំគាត់ឲ្យសួរចម្លើយអ្នកទោសសង្គ្រាមជនជាតិវៀតណាម។ សាក្សីបានថ្លែងថា បទសម្ភាសន៍ និងចម្លើយសារភាពរបស់អ្នកទាំងនោះ ត្រូវបានអាត់ច័សម្លេងទុក។ សាក្សី ក៏មិនបានឆ្លើយតបនឹងសំណួរមួយចំនួន នៅពេលសួរថាតើចម្លើយសារភាពទាំងនេះ ត្រូវបានខ្មែរក្រហមយកទៅចាក់ផ្សាយតាមវិទ្យុ។

ចំណែកឯជនជាតិចាម សាក្សីបានចង្អុលបង្ហាញថា បក្សបានចាត់ទុកក្រុមជនទាំងនេះថា ជាជនជាតិភាគតិច។ តាមតែដឹង ពួកគេក៏បានចូលរួមចំណែកធ្វើបដិវត្តន៍មុនទីក្រុងភ្នំពេញត្រូវបានផ្តួលរំលំ ប៉ុន្តែពួកគេត្រូវបានដាក់ឲ្យនៅឯកោពីបក្សក្រោយឆ្នាំ១៩៧៥។ **ឌុច** បានពន្យល់ថា ជនជាតិឥស្លាមត្រូវបានគេជម្លៀសទៅកាន់ភាគខាងជើង និងភាគខាងជើងឆៀងខាងលិច (ទិសពាយព្យ) ក្នុងការ "លត់ដំខ្លួន" និងដើម្បីធ្វើឲ្យប្រាកដថា ពួកគេបានលះបង់ចោលការប្រតិបត្តិសាសនាឥស្លាម។ ទោះបីជាយ៉ាងណា សាក្សីនៅតែប្រកាន់ជំហរថា បក្សកុម្មុយនីស្តកម្ពុជា មិនបានចាត់ទុកជនជាតិឥស្លាមជាសាសនាប្រតិកិរិយាឡើយ ប៉ុន្តែបក្សបានចាត់ទុកសាសនិកកាតូលិក និងសាសនិកប្រូតេសស្តង់ថា ជាក្រុមប្រតិកិរិយា។

***ការចាប់ខ្លួនជនបរទេសចេញនៅឆ្នេរសមុទ្រកម្ពុជា ៖*** **ឌុច** បានគូសបញ្ជាក់ថា ការចាប់ខ្លួនពួកបស្ចិមប្រទេស គឺត្រូវបានធ្វើឡើងដោយកងពលលេខ១៦៤ ជាកងនាវារបស់កម្ពុជាប្រជាធិបតេយ្យ ដែលមានកម្មាភិបាល **មាស មុត** (ប្រធានកងពល) ស្ថិតក្រោមការបញ្ជារបស់ **សុន សេន** ប៉ុន្តែមិនមែនចេញមកពីក្រសួងការបរទេសទេ។ **ឌុច** បានបដិសេធចំពោះការអះអាងរបស់មេធាវី **លីម៉ា ង្វៀន** ដែលថា មានជនជាតិអូស្ត្រាលីចំនួន ២រូប (បុរសជនជាតិអង់គ្លេស និងជនជាតិនូវែលសេឡង់) និងជនជាតិអាមេរិកាំងចំនួន ៣រូបត្រូវបានចាប់ខ្លួន។ សាក្សីបានរៀបរាប់ថា មានជនជាតិបរទេសតែ ៤នាក់ ប៉ុណ្ណោះ ដែលត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១។ ជនបរទេសទាំងបួនរូបនេះ ត្រូវបានខ្មែរក្រហមយល់ឃើញថា ជាភ្នាក់ងារចារកម្ម និង ចាត់ទុកពួកគេក្នុងនាមជា *"អ្នកទោសពិសេស"* ។ **ឌុច** បានពិពណ៌នាថា ពួកគេទាំងនេះត្រូវបានយកទៅដាក់ឃុំឃាំងនៅក្នុងបន្ទប់ពិសេស និងចាត់អ្នកសួរចម្លើយដែលមានបទពិសោធន៍ ២ ឬ ៣នាក់ រួមទាំងអ្នកបកប្រែភាសា។ នៅទីបញ្ចប់ពួកគេទទួលបានជោគវាសនាដូចគ្នា គឺត្រូវ *កម្ទេចចោល* ។ **ឌុច** បានបន្ថែមថា **នួន ជា** បានបញ្ជាឱ្យគាត់ដុតសាកសពជនបរទេសចំនួន២នាក់ ដើម្បីកុំឲ្យសល់ដានពីការកម្ទេចនេះ។ ផ្ទុយទៅវិញ អ្នកនេសាទជនជាតិថៃទាំងឡាយដែលត្រូវបានខ្មែរក្រហមចាប់បាន គឺមិនត្រូវបានចាត់ទុកថា ជាអ្នកទោសពិសេសទេ ប៉ុន្តែពួកគេក៏ត្រូវសម្លាប់ដែរក្រោយពីចាប់ខ្លួនបាន។

***ទំនាក់ទំនងរវាង "អង្គការ" និង មន្ទីរស-២១ ៖*** យោងតាមសាក្សីបានឲ្យដឹងថា "អង្គការ" សំដៅលើ **ប៉ុល ពត** និង **នួន ជា**។ **ឌុច** បានពន្យល់ថា "អង្គការ" បានផ្ញើឯកសារនានាទៅមន្ទីរស-២១ តាមរយៈនីរសាររបស់ខ្លួន។ ក្នុងពេលដែល **សុន សេន** នៅជាអ្នកគ្រប់គ្រងមន្ទីរស-២១ គាត់មានកម្មាភិបាលពីរនាក់ឈ្មោះ **ប៉ាន់** និង **នឿន** មានមុខងារជាអ្នកនាំសារ (នីរសារ) ពីអង្គការទៅមន្ទីរស-២១។ នៅពេលដែល **នួន**

**ជា** ចូលជំនួសតំណែង **សុន សេន** ចាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ គាត់មាននីរសារថ្មីពីរនាក់ ឈ្មោះ មិត្ត **ទឿង**[13] និងមិត្ត **សូត្រ** ហៅក្រៅ "*ជីវ*" ។ **ឌុច** បានរម្លឹកថា ក្រោយមកមិត្ត **លីន** បានចូលខ្លួនមកបំពេញការងារជំនួសមិត្ត **ទឿង** និងមិត្ត **ជីវ** ប៉ុន្តែគាត់មិនបានដឹងថា មានអ្វីកើតឡើងចំពោះអតីតនីរសារទាំងពីរនាក់នោះទេ។ តាមការរៀបរាប់នេះ បានបង្ហាញថា សមមិត្ត **លីន** បានបញ្ជូនសាររបស់ **នួន ជា** ឲ្យទៅគាត់ (**ឌុច**) ចំណែកឯសមមិត្ត **គី** (ប្រធានការិយាល័យក-៧) ជាអ្នកនាំសារពី **ប៉ុល ពត**។ **ឌុច** ក៏បានលើកឡើងថា **នួន ជា** គឺជាអ្នកដែលបានណែនាំគាត់ឲ្យស្គាល់សមមិត្ត **ប៉ង់**[14]។

## គ. សេចក្តីសង្ខេបពីការសួរដេញដោលរបស់អង្គជំនុំជម្រះទៅកាន់សាក្សី ឌុច

អង្គជំនុំជម្រះតាមរយៈលោកចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** បានចាប់ផ្តើមសួរដេញដោល **ឌុច** ដោយផ្តោតជាពិសេសអំពីខ្មាំងទាំងបីប្រភេទរបស់បក្សកុម្មុយនីស្តកម្ពុជា និងគោលនយោបាយចំពោះសត្រូវ ដែលត្រូវបានអនុម័តក្នុងទសវត្សន៍ឆ្នាំ១៩៦០។ **ឌុច** បានពន្យល់ថា ប្រភេទខ្មាំងទីមួយ គឺជាខ្មាំងដែលបក្សត្រូវតែអូសទាញឲ្យមកចូលរួមធ្វើជាកម្លាំងបដិវត្តន៍ ចំណែកឯ ខ្មាំងប្រភេទទីពីរ គឺជាប្រជាជនធម្មតាដែលនៅប៉ាលហាល ឬស្ទាក់ស្ទើរក្នុងការចូលរួមជាមួយកម្លាំងបដិវត្តន៍។ ដោយឡែក ខ្មាំងប្រភេទចុងក្រោយ គឺខ្មាំងដែលមានភាព *"សាហាវឃោរឃៅ"* ដែលត្រូវតែធ្វើឲ្យពួកគេនៅឯកា *"ឯកាខ្មាំង"* និងត្រូវតែប្រឆាំងតបតជាដាច់ខាត។

ទ្រឹស្តីនៃការបែងចែកខ្មាំងនៅតែមានការអនុវត្តជាបន្តបន្ទាប់ ទោះបីជាក្រោយពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានរំដោះភូមិភាគមួយចំនួននៅឆ្នាំ១៩៧១ ប៉ុន្តែវាគ្រាន់តែជា *"ទ្រឹស្តី"* ប៉ុណ្ណោះ ពីព្រោះគ្មានការអនុវត្តគោលនយោបាយបើកទូលាយណាមួយ ដើម្បីឲ្យប្រជាជនទូទៅអាចទទួលយកបាននោះទេ។ ផ្ទុយពីគោលការណ៍នេះ គេមិនឃើញមានការបើកចំហ ឬការធ្វើសកម្មភាពបញ្ចុះបញ្ចូលផ្សេង ដើម្បីឲ្យមនុស្សដែលបក្សចាត់ទុកថាជាខ្មាំងអាចចូលរួមក្នុងកម្លាំងតស៊ូបដិវត្តន៍ សូម្បីតែមនុស្សបានឆ្លងកាត់តំបន់ខ្មាំង ចូលមកព្រំដែនតំបន់រំដោះក៏មិនបានដែរ។ លើសពីនេះ បន្ទាប់ពីការចាប់ខ្លួន *"ជនក្បត់ទាំងប្រាំពីរនាក់"* បក្សកុម្មុយនីស្តកម្ពុជា បានផ្សព្វផ្សាយតាមវិទ្យុរបស់រណសិរ្សបង្រួបបង្រួមជាតិ និងរដ្ឋាភិបាលបង្រួបបង្រួមជាតិ (គ្រុង និង ហ៊ុង) ពីគោលនយោបាយរួបរួមជាតិ ដែលព្យាយាមអន្ទងចិត្តប្រជាជនឲ្យមើលឃើញថា បក្សមិនមានការបែងចែកវណ្ណៈសង្គម ប្រកាន់និន្នាការ ឬភាពលម្អៀងផ្នែកនយោបាយ ជំនឿសាសនា ហើយក៏មិនប្រកាន់អតីតកាលរបស់ជនណាម្នាក់ឡើយ (បក្សនឹងទទួលយកមនុស្សគ្រប់រូប ដើម្បីចូលរួមកសាងសង្គមថ្មីជាមួយគ្នា) លើកលែងតែជនក្បត់ទាំងប្រាំពីរនាក់។ **ឌុច** បានឲ្យដឹងថា គោលនយោបាយនេះ មិនដែលត្រូវបានអនុវត្តទេ។

ចំពោះការជម្លៀសប្រជាពលរដ្ឋនៅស្រុកឧត្តុង្គ ទីក្រុងភ្នំពេញ និងខេត្តកំពង់ធំ ក៏ដូចជា ការជម្លៀសជាបន្តបន្ទាប់ សាក្សី **ឌុច** បានឲ្យដឹងថា គ្មានទឡ្ហីករណ៍ ឬ មធ្យោបាយណាមួយ ដែលខ្មែរក្រហមប្រើប្រាស់ដើម្បីជួយសម្រួលដល់ប្រជាជនឡើយ។ គាត់បានដឹងពីការជម្លៀសពីបងថ្លៃប្រុសរបស់គាត់ ក៏ដូចជា តាមរយៈវគ្គអប់រំរៀនសូត្រមួយចំនួនដែលគាត់បានចូលរួម។

បន្ថែមលើនេះ សាក្សីបានអធិប្បាយលើសំណេររបស់អតីតបុគ្គលិកមន្ទីរស-២១ ឈ្មោះ **ម៉ម ណៃ** ទាក់ទងនឹងការបោះបង់ចោលទ្រព្យសម្បត្តិផ្ទាល់ខ្លួន ទ្រព្យសម្បត្តិឯកជន មនោសញ្ចេតនាចំពោះមនុស្សដែលខ្លួនស្រឡាញ់ ក៏ដូចជា ចំណងមេត្រីភាពនៅក្នុងក្រុមគ្រួសារ ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តបម្រើផល

ប្រយោជន៍ជូនបក្ស និងសមូហភាព។ **ឌុច** បានថ្លែងប្រាប់តុលាការថា *"ការដឹងគុណចំពោះមាតាបិតា គេមិនចាត់ទុកថា មានសារៈសំខាន់ទេ ។ គេឲ្យមនុស្សយើងម្នាក់ៗដឹងគុណបក្ស ពោលគឺយកបក្សជាធំ"* ។ ដើម្បីបញ្ជាក់ពីបញ្ហានេះ លោកចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** បានចោទសួរសាក្សី **ឌុច** អំពីការចាប់ខ្លួន និង សម្លាប់បងថ្លៃប្រុសរបស់គាត់ ក៏ដូចជា ការសម្រេចចិត្តរបស់បក្សក្នុងការចាប់ខ្លួន និង កម្ទេចសាច់ញាតិរបស់ជនជាប់ចោទ **នួន ជា** ដូចជា ក្មួយស្រី និងក្មួយប្រុស ដែលត្រូវជាសាច់ថ្លៃរបស់ជនជាប់ចោទ។ **ឌុច** បាននិយាយថា ជាគោលការណ៍ មានតែ **ប៉ុល ពត** និង **នួន ជា** តែប៉ុណ្ណោះ ដែលអាចចេញបញ្ជាឲ្យចាប់ខ្លួនមនុស្ស។

នៅពេលដែលការជជីកដេញដោលបង្វែរទៅ **ខៀវ សំផន** សាក្សី **ឌុច** បានរៀបរាប់ថា ជនជាប់ចោទ **ខៀវ សំផន** មានទំនាក់ទំនងយ៉ាងជិតស្និទជាមួយ **ប៉ុល ពត**។ សាក្សីបន្តថា **ខៀវ សំផន** គឺ ជាលេខាធិការផ្ទាល់របស់ **ប៉ុល ពត** នៅគណៈមជ្ឈិម។ គាត់ទទួលខុសត្រូវលើការិយាល័យរបស់លេខា **ប៉ុល ពត**។ ផ្អែកតាម **ឌុច** ចំណុចនេះ មានន័យថា ជនជាប់ចោទទទួលខុសត្រូវលើឯកសារចេញចូល ដូច្នេះ គាត់អាចដឹងការងារសំខាន់ៗ និងសេចក្តីសម្រេចរបស់ **ប៉ុល ពត**។ តួនាទីជាក់លាក់របស់ **ខៀវ សំផន** គឺនៅតែមិនច្បាស់ ទោះបីជាមានការសួរដេញដោលរបស់ចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** ប៉ុន្តែអ្វីដែលច្បាស់ គឺថា ជនជាប់ចោទបានដឹងពីព័ត៌មានសំខាន់ៗដែលផ្ញើទៅការិយាល័យនេះ។

ប្រធានអង្គជំនុំជម្រះ **និល ណុន** ក៏បានធ្វើការចោទសួរសំណួរមួយចំនួនទៅសាក្សី **ឌុច** ផងដែរ។ សាក្សីបានបញ្ជាក់ថា **ប៉ុល ពត** គឺជាគណៈប្រធានរដ្ឋ និងក៏ជានាយករដ្ឋមន្រ្តី។ សាក្សីបានថ្លែងបន្តថា មានឧបនាយករដ្ឋមន្ត្រីចំនួន ៣រូប ដែលបានជួយសម្រួលការងារ **ប៉ុល ពត** រួមមាន ៖ ឧបនាយករដ្ឋមន្ត្រីទី១ **អៀង សារី** ជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ចំណែកឧបនាយករដ្ឋមន្ត្រីទី២ **សុន សេន** ជារដ្ឋមន្ត្រីនៃក្រសួងការពារជាតិ និង ឧបនាយករដ្ឋមន្ត្រីទី៣ **វ៉ន វ៉េត** ជារដ្ឋមន្ត្រីទទួលបន្ទុកផ្នែកសេដ្ឋកិច្ច។ លើសពីនេះ អង្គការរដ្ឋត្រូវបានបែងចែកជាពីរប្រភេទ ៖ (១) បណ្តាក្រសួងដែលទទួលខុសត្រូវទូទាំងប្រទេស និង (២) គណៈកម្មាធិការថ្នាក់មន្ទីរ ឬការិយាល័យដែលទទួលខុសត្រូវនៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។ ដោយឡែកចំពោះមន្ទីរស-២១ **ឌុច** បានថ្លែងថា មន្ទីរនេះ គឺស្ថិតនៅកម្រិតថ្នាក់ស្រុក ពោលគឺជាគណៈកម្មាធិការថ្នាក់ស្រុក។ លើសពីនេះ ទោះបីជាប្រធានអង្គជំនុំជម្រះបានយោងលើឯកសារមួយ ហើយបានសួរសំណួរទៅ **ឌុច** ថាតើបុគ្គលណានៅគណៈមជ្ឈិមដែលមានសិទ្ធិអំណាចក្នុងការសម្រេចកម្ទេចទាំងក្នុង និងក្រៅបក្ស? បន្ទាប់ពីបានអានសម្រង់ដកស្រង់ពីឯកសារយោងនោះ **ឌុច** បានអធិប្បាយពីការយល់ឃើញរបស់គាត់ថា *"បើនៅជុំវិញមន្ទីរមជ្ឈិម គឺគណៈមន្ទីរមជ្ឈិមជាអ្នកសម្រេច។ កថាខណ្ឌនេះ បានន័យថា* ***ខៀវ សំផន*** *ជាអ្នកសម្រេច។ នេះជាគោលការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌនេះ"* ។ ទោះបីជាមានការលើកឡើងថា **ខៀវ សំផន** ជាអ្នកទទួលបន្ទុកលើឯកសារ ឬក្រដាសស្នាម និងមានមុខងារមើលការខុសត្រូវលើអង្គភាពមួយចំនួនក៏ដោយ ក៏សក្ខីកម្មក្រោយៗរបស់ **ឌុច** បានបង្ហាញឲ្យឃើញថា ជនជាប់ចោទ **ខៀវ សំផន** ទំនងជាបានចូលរួមធ្វើការសម្រេចក្នុងការសម្លាប់បុគ្គលមួយចំនួននៅក្នុងគណៈមជ្ឈិម។

### ឃ. ការសួរដេញដោលសាក្សី ឌុច ពីសំណាក់ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា

មេធាវីការពារក្តីជាតិ និងអន្តរជាតិទាំង ៣រូប របស់ **នួន ជា** រួមមាន មេធាវី **ម៉ៃខល ផេស្តមិន** មេធាវី **ហ្សាស្តី ប៉ៅ** និងមេធាវី **សុន អរុណ** បានប្រើប្រាស់ពេលវេលា ២ថ្ងៃ ក្នុងការសួរដេញដោលសាក្សី **ឌុច** លើប្រធានបទមួយចំនួន ដើម្បីឆ្លុះបង្ហាញឲ្យឃើញពីភាពមិនត្រឹមត្រូវនៃចម្លើយរបស់សាក្សីដែលបានឆ្លើយកន្លង

មក និងផ្ទៀងផ្ទាត់នឹងចម្លើយចំពោះមុខអង្គជំនុំជម្រះ។ ក្រុមមេធាវីការពារក្តី ក៏បានព្យាយាមធ្វើការចោទប្រកាន់ដោយចំពោះភាពមិនគួរឲ្យជឿជាក់របស់សាក្សី **ឌុច** ដែរ។

### *ឃ.១. ការទម្លាក់គ្រាប់បែករបស់អាមេរិកាំង និងមន្ទីរសន្តិបាល ម-១៣*

សាក្សី **ឌុច** បានរម្លឹកឡើងវិញថា ក្នុងអំឡុងពេលនៃការទម្លាក់គ្រាប់បែករបស់អាមេរិកាំងមកលើទឹកដីនៃប្រទេសកម្ពុជា បុគ្គលិក និងអ្នកទោសនៅមន្ទីរសន្តិបាលម-១៣ (មន្ទីរសន្តិសុខ) បាននាំគ្នាលាក់ខ្លួននៅក្នុងលេណដ្ឋាន ដើម្បីការពារសុវត្ថិភាពផ្ទាល់ខ្លួន។ បក្សកុម្មុយនីស្តកម្ពុជាមិនបានរាយការណ៍ពីចំនួនអ្នកស្លាប់ និងអ្នករងរបួសពីការទម្លាក់គ្រាប់បែកនេះឡើយ ដោយសារតែ **ប៉ុល ពត** មិនចង់ឲ្យប្រជាជនមានការភ្ញាក់ផ្អើល និងភ័យខ្លាច។ **ឌុច** បានឆ្លើយតបនឹងសំណួរមួយចំនួន គឺនៅពេលដែលមានការណែនាំពីអង្គជំនុំជម្រះឲ្យឆ្លើយតបសំណួរ។ គាត់បានទទួលស្គាល់ថា គាត់មិនបានដឹងពីចំនួនប្រជាជនដែលបានស្លាប់ និងរបួសដោយសារការទម្លាក់គ្រាប់បែកទេ ប៉ុន្តែគាត់បានដឹងថា លទ្ធផលនៃការទម្លាក់គ្រាប់បែក គឺជាមូលហេតុដែលបណ្តាលឲ្យមានការកើនឡើងនៃចំនួនអ្នកទោសនៅក្នុងមន្ទីរម-១៣ ព្រោះតែមានប្រជាជនកាន់តែច្រើនបាននាំគ្នារត់ចូលតំបន់រំដោះ។ **ឌុច** បានឲ្យដឹងបន្តថា *"គោលគំនិតនៃការកម្ទេចខ្មាំងនាពេលនោះ ឲ្យតែចូលតំបន់រំដោះ គេចាត់ទុកថា ជាតិញ ដែលត្រូវតែកម្ទេច"* (សម្រង់ពីកំណត់ហេតុយកចម្លើយ ទំព័រ ២៩ ថ្ងៃទី៣ មេសា ២០១២)។

### *ឃ.២. តួនាទីរបស់ ឌុច ក្នុងការសួរចម្លើយអ្នកទោស*

**ឌុច** មានតួនាទីជាប្រធានមន្ទីរសន្តិសុខដ៏ល្បីល្បាញចំនួនពីរ ដែលជាកន្លែងឃុំឃាំងគួរឲ្យភ័យខ្លាចបំផុត គឺមន្ទីរសន្តិសុខ ម-១៣ និងមន្ទីរសន្តិសុខ ស-២១ ។ **ឌុច** ត្រូវបានតុលាការរកឃើញថា មានការជាប់ពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋដែលបានប្រព្រឹត្តនៅមន្ទីរស-២១ ប៉ុន្តែគាត់មិនត្រូវបានតុលាការធ្វើការចោទប្រកាន់ពីបទឧក្រិដ្ឋដែលប្រព្រឹត្តនៅមន្ទីរម-១៣ទេ។ ដើម្បីបង្ហាញឲ្យឃើញភាពផ្ទុយគ្នាចំពោះការអះអាងរបស់សាក្សី **ឌុច** ដែលលើកឡើងថា គាត់មិនធ្លាប់បានធ្វើទារុណកម្មអ្នកទោសដោយផ្ទាល់ក្នុងពេលសួរចម្លើយ មេធាវី **ផេស្តមិន** បានសួរដេញដោលអំពីសេចក្តីថ្លែងការណ៍មួយចំនួន ដែលបង្ហាញថា **ឌុច** និងអតីតអ្នកទោសមួយចំនួន បានរាយការណ៍អំពីការសួរចម្លើយ និងការវាយដំ និងការធ្វើទារុណកម្មនៅមន្ទីរម-១៣។ មេធាវី **ផេស្តមិន** បានដកស្រង់សម្តីរបស់ **ឌុច** អំឡុងពេលដែលគាត់បានឆ្លើយនៅក្នុងសវនាការសំណុំរឿង០០១ ដែលមានខ្លឹមសារដូចតទៅ ៖ *"ខ្ញុំត្រូវប្រើពេលស្ទើរតែមួយខែដើម្បីបញ្ចប់។ ដូច្នេះហើយការធ្វើទារុណកម្ម ការវាយដំនៅក្នុងពេលសួរចម្លើយក៏មានដែរ។ ខ្ញុំបានព្យាយាមយ៉ាងខ្លាំង ដើម្បីធ្វើការងារនោះឲ្យចប់សព្វគ្រប់"* ។ *គួរកត់សម្គាល់ថា អ្វីដែលមេធាវីសុំឲ្យពន្យល់បន្ថែម គឺអត្ថន័យនៃឃ្លាចុងក្រោយ ៖ "ខ្ញុំបានព្យាយាមយ៉ាងខ្លាំង"*។[1] សាក្សី **ឌុច** បានបដិសេធមិនឆ្លើយតបនឹងសំណួររបស់មេធាវី **ផេស្តមិន** ជាពិសេស រាល់សំណួរទាំងឡាយណាដែលពាក់ព័ន្ធនឹងអង្គហេតុនៅមន្ទីរម-១៣ និងជាញឹកញាប់បានប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយសំណួរដែលអាចដាក់ពិរុទ្ធលើខ្លួនឯង។

[1] បន្ថែមពីអ្នកបកប្រែ: ប្រតិចារឹកតុលាការ ទំព័រទី៧ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២

នៅពេលដែលមេធាវីចោទសួរសេចក្ដីថ្លែងការណ៍មួយដកស្រង់ពីសៀវភៅរបស់លោក **ហ្វ្រង់ស្វ័រ ប៊ីហ្សូត** សាក្សី **ឌុច** បានទាញហេតុផលថា កាលណាសៀវភៅត្រូវបានសរសេរចងក្រងជាលក្ខណៈប្រលោមលោក ដូច្នេះ ព័ត៌មានលម្អិតជាច្រើនដែលគេសរសេរថាជាការពិត នោះគឺគ្រាន់តែជាការប្រឌិតប៉ុណ្ណោះ។

ពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់សាក្សី **ឌុច** នៅមន្ទីរស-២១ ដែលត្រូវបាន អ.វ.ត.ក បានធ្វើការផ្ដន្ទាទោសរួចហើយនោះ **ឌុច** បានសារភាពថា គាត់ធ្លាប់បានទះកំផ្លៀងអ្នកទោសពីរ ឬបីដង ប៉ុន្តែគាត់បានបដិសេធថា គាត់មិនធ្លាប់បានធ្វើទារុណកម្ម ឬ សម្លាប់អ្នកទោសណាម្នាក់នោះទេ។ **ឌុច** បានទទួលឯកសារឲ្យពិនិត្យឡើងវិញពីការរក្សាជំហរដែលថា គាត់មិនបានឈរមើល ឬ មើលឃើញការធ្វើទារុណកម្មអ្នកទោសដោយផ្ទាល់ភ្នែកទេ។ ផ្ទុយទៅវិញ **ឌុច** បានអះអាងថា គាត់រវល់ខ្លាំងណាស់ គាត់គ្មានពេលឯណាទៅទាត់ធាក់អ្នកទោសទេ ប៉ុន្តែសក្ខីកម្មរបស់សាក្សីម្នាក់នៅក្នុងសំណុំរឿង០០១ បានលើកឡើងថា **ឌុច** បានធ្វើការសួរចម្លើយអ្នកទោសដោយផ្ទាល់ និង បានទាត់អ្នកទោសបរទេសម្នាក់នៅក្នុងចំណោមបួននាក់ផ្សេងទៀត។ សាក្សី **ឌុច** បានពន្យល់លើចំណុចនេះថា គាត់ពិតជាមានវត្តមានក្នុងអំឡុងពេលសួរចម្លើយអ្នកទោសបរទេសនោះមែន ដើម្បីសង្កេតតាមដានពីគុណភាពនៃការបកប្រែភាសា។ សាក្សី **ឌុច** នៅតែរក្សាជំហរថា គាត់ធ្លាប់បានសួរចម្លើយលើអ្នកទោសតែម្នាក់ គឺសមមិត្ត **កុយ ធួន** ។ នៅពេលសាក្សីប្រឈមនឹងចម្លើយដែលគាត់បានឆ្លើយនៅតុលាការយោធាកាលពីឆ្នាំ១៩៩៩ស្ដីពីការសួរចម្លើយទៅលើអ្នកទោសឈ្មោះ **ស៊ាត ឆៃ** សាក្សីបកស្រាយថា គាត់ប្រហែលជាភ្លេចអំពីបញ្ហានេះ ព្រោះគាត់គ្រាន់តែបានសួរចម្លើយលើអ្នកទោសនោះដោយសង្ខេបប៉ុណ្ណោះ។ សាក្សី **ឌុច** បានពន្យល់ថា គាត់បានបញ្ជូនលិខិតពី **សុន សេន** ឲ្យទៅអ្នកទោសមើលដើម្បីជំរុញឲ្យគេទទួលសារភាព។

នៅពេលមានសំណួរថា ហេតុអ្វីបានជាគាត់ប្រាប់ទៅសហចៅក្រមស៊ើបអង្កេតថា គាត់មិនធ្លាប់បានឮការប្រើប្រាស់ពាក្យ "ក្រុមក្ដៅ ក្រុមត្រជាក់ និងក្រុមអង្កៀម" រហូតទាល់តែគាត់បានមើលខ្សែភាពយន្តឯកសារមួយ និពន្ធដោយលោក **រិទ្ធី ប៉ាន់**[15] **ឌុច** បានគូសបញ្ជាក់ថា វាមិនមែនជារឿងងាយស្រួលក្នុងការចងចាំរាល់អ្វីដែលគាត់បានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត ដែលបានសម្ភាសគាត់ជាង ៣០លើក ។ លើសពីនេះ សាក្សីបានថ្លែងថា គាត់បានព្យាយាមបំភ្លេចការចងចាំដ៏ជូរចត់ពីអតីតកាលរបស់គាត់។ ទោះបីជាយ៉ាងណា **ឌុច** បានទទួលស្គាល់ថា គាត់បានបង្រៀនបច្ចេកទេសក្នុងការសួរចម្លើយដល់បុគ្គលិកក្រោមឱវាទនៅមន្ទីរស-២១ ការថ្លែងបែបនេះបានញាំងឲ្យមេធាវី **ផេស្ដមិន** សួរផ្ទុចភ្លាមៗ ថាហេតុអ្វីបានជាគាត់និយាយកុហកមន្ត្រីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត? ទីបំផុត សាក្សី **ឌុច** បានឆ្លើយថា គាត់មានការភ័ន្តច្រឡំ ដោយសារតែព្រឹត្តិការណ៍នោះបានកើតឡើងយូរហើយ។

### *ឃ.៣. ចំណាររនៅលើចម្លើយសារភាព ធ្វើដោយថ្នាក់ដឹកនាំ*

**ឌុច** បានថ្លែងថា ការធ្វើចំណាររនៅលើចម្លើយសារភាព ត្រូវបានចាប់ផ្ដើមបន្ទាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ព្រោះជាពេលដែល **នួន ជា** បានទទួលបន្ទុកការងារជំនួស **សុន សេន** និងជាអ្នកគ្រប់គ្រងផ្ទាល់លើ **ឌុច** ។ សាក្សីបានថ្លែងថា គាត់មិនបានពឹងផ្អែកទាំងស្រុងទៅលើកាលបរិច្ឆេទ ដើម្បីអាចចំណាំពីចំណារទាំងនោះទេ ប៉ុន្តែវាពិតជាចំណារដៃដែលលើកឡើងថា "អានរួចហើយ" ជាចំណាររបស់ **នួន ជា** ។ **ឌុច** បានអត្ថាធិប្បាយថា គាត់បានឃើញចម្លើយសារភាពដែលមានចំណារទាំងនេះនៅឆ្នាំ១៩៨៩ ឬឆ្នាំ១៩៩០។ ទោះបីជាយ៉ាងណា **ឌុច** បានបង្ហាញឲ្យឃើញថា គាត់មិនធ្លាប់បានចូលរួមវគ្គបណ្ដុះបណ្ដាលជាក់លាក់ ដើម្បី

ឲ្យគាត់អាចវិភាគសំណេរដៃរបស់បុគ្គលណាម្នាក់ឡើយ។ មេធាវី **ផេស្តមិន** បានសួរផ្ទុចសាក្សី ដោយលើកឡើងនូវចម្លើយសារភាពមួយចំនួនដែលមានចំណារ ដើម្បីបង្ហាញថា នេះគឺជាការចំណាំរបស់សាក្សី មិនមែនជាការស្គាល់ទេ។ មេធាវីបានតតាំងសាក្សីដោយដកស្រង់អង្គហេតុមិនស៊ីចង្វាក់មួយចំនួន នៅពេលគាត់បានឆ្លើយជូនការិយាល័យសហចៅក្រមស៊ើបអង្កេត។ សាក្សី **ឌុច** បានទទួលស្គាល់ថា ពេលខ្លះគាត់អាចមានការភ័ន្តច្រឡំអំពីព្រឹត្តិការណ៍ និងបានឲ្យដឹងថា ការសន្និដ្ឋានអំពីចំណារណាមួយធ្វើឡើងដោយអ្នកគ្រប់គ្រងណាម្នាក់នោះ គឺឈរលើមូលដ្ឋាននៃការយល់ដឹងផ្ទាល់ខ្លួន តាមរយៈការពិនិត្យមើលលើសំណេរទាំងនោះ និងការចុះកាលបរិច្ឆេទនៅក្នុងឯកសារ ឬចម្លើយសារភាពទាំងនោះ។ **ឌុច** បានយល់ស្របថា រាល់ចម្លើយសារភាពដែលបានផ្ញើជូនទៅគណៈគ្រប់គ្រងរបស់គាត់ គឺមិនត្រូវបានគេបញ្ជូនត្រឡប់មកមន្ទីរស-២១វិញទេ។ សាក្សីក៏បានទទួលស្គាល់ថា គាត់ទើបតែបានឃើញចំណារពីអ្នកគ្រប់គ្រងនៅលើចម្លើយសារភាព នៅពេលដែលបុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបង្ហាញគាត់នៅខែមេសា ឆ្នាំ១៩៩៩។

### *ឃ.៤. ការជួលវិលំទីក្រុងភ្នំពេញ*

**ឌុច** បានបញ្ជាក់ថា **ប៉ុល ពត** និង **នួន ជា** ជាអ្នកមានអំណាចសម្រេចចេញបទបញ្ជាចុងក្រោយដើម្បីឈានឆ្ពោះទៅរកការ "រំដោះ" ទីក្រុងភ្នំពេញ។ ដោយឡែកនៅថ្នាក់តំបន់ មានថ្នាក់លេខាធិការប្រចាំតំបន់ជាអ្នកមានអំណាចក្នុងការអនុវត្តវិធានការទូទៅតាមតំបន់នីមួយៗ ប៉ុន្តែមិនមាននរណាម្នាក់ក្នុងចំណោមពួកគេនៅរស់រានមានជីវិតទេ។ **ឌុច** បានស្នើសុំកែប្រែចម្លើយរបស់ខ្លួន ដោយបញ្ជាក់អះអាងថា មានលេខាភូមិភាគម្នាក់ដែលនៅរស់ គឺឯកឧត្តម **ហេង សំរិន**។[16] **ឌុច** ក៏បានផ្តល់សក្ខីកម្មអំពីការទំហំព្រំដែនជាក់លាក់នៃតំបន់រំដោះ។

### *ឃ.៥. ការចោទប្រកាន់ពីសុចរិតភាពរបស់សាក្សី*

ការសួរដេញដោលរបស់ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **នួន ជា** គឺបង្ហាញឲ្យឃើញពីភាពមន្ទិលសង្ស័យ និងភាពមិនគួរឲ្យជឿជាក់របស់ **ឌុច** ។ ក្រុមមេធាវីបានធ្វើតេស្តសាកល្បងពីគុណវុឌ្ឍិរបស់សាក្សីទៅលើចំណារនានាដែលមាននៅលើចម្លើយសារភាព និងសំណេរដៃរបស់ **នួន ជា** ។ មេធាវី **ផេស្តមិន** បានព្យាយាមបង្ហាញឲ្យឃើញថា ការអះអាងរបស់ **ឌុច** ចំពោះចំណារលើចម្លើយសារភាពទាំងនោះ គឺគ្រាន់តែជាការប៉ាន់ស្មាន ដោយផ្អែកតាមកាលបរិច្ឆេទដែលមាននៅលើឯកសារទាំងនោះ។ សំណួរផ្សេងទៀតដែលបានចោទសួរសាក្សី **ឌុច** ពាក់ព័ន្ធនឹងបទសម្ភាសន៍របស់គាត់ជាមួយនឹងអ្នកសារព័ត៌មាន ដូចជា លោក **គ្រីស្តូហ្វ័រ ប៉េស៊ូ** (Christophe Peschoux)[17] លោក **នីក ដងឡុប** (Nic Dunlop) និងលោក **នេត ថាយ័រ** (Nate Thayer) ដើម្បីចង្អុលបង្ហាញពីភាពមិនស៊ីចង្វាក់គ្នានៅក្នុងចម្លើយរបស់សាក្សី។ **ឌុច** បានបង្ហាញឆន្ទៈមិនសហការណ៍ និងបដិសេធមិនឆ្លើយសំណួរដោយហេតុផលផ្សេងៗ។ **ឌុច** តែងតែលើកឡើងពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរដែលដាក់ពិរុទ្ធភាពប្រឆាំងលើខ្លួនឯង។ នៅពេលខ្លះ អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ឲ្យសាក្សីឆ្លើយសំណួរ ហើយពេលខ្លះទៀត អង្គជំនុំជម្រះបានយល់ស្របតាមហេតុផលរបស់ **ឌុច** និងណែនាំមិនឲ្យសាក្សីឆ្លើយតបនឹងសំណួររបស់មេធាវី ដោយសារអង្គជំនុំជម្រះយល់ឃើញថា សំណួរទាំងនោះមិនមានភាពជាប់ពាក់ព័ន្ធ ឬដើម្បីជៀសចម្លើយដែលអាចដាក់ពិរុទ្ធភាពដល់សាក្សី។

ជាមួយគ្នានោះដែរ ការសួរដេញដោលគុណវុឌ្ឍិរបស់ **ឌុច** អំពីដំណើរការប្រព្រឹត្តទៅរបស់គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមផងដែរ។ មេធាវី **ហ្សាស្ដី ប៉ៅ** បានព្យាយាមបង្ហាញឲ្យឃើញថា សាក្សី **ឌុច** អាចពិនិត្យមើលព័ត៌មានផ្សេងៗនៅក្នុងសំណុំរឿង ក៏ដូចជា បានធ្វើការសិក្សាស្រាវជ្រាវផ្ទាល់ខ្លួន ប្រមូលនឹងព័ត៌មានដែលគាត់អាចរកបានពីសៀវភៅ ខ្សែភាពយន្តឯកសារ ព្រមទាំងមធ្យោបាយផ្សេងៗទៀត ដើម្បីយកធ្វើជាមូលដ្ឋានក្នុងការផ្តល់សក្ខីកម្ម ជាជាងការផ្តល់ចម្លើយដោយផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួន។ **ឌុច** បានសារភាពថា ការយល់ដឹងរបស់គាត់អំពីមុខងាររបស់គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម គឺដឹងត្រឹមតែជា "គោលការណ៍"។ សាក្សីបានបន្តថា គាត់ពិតជាបានអានសៀវភៅមួយចំនួន និងមើលខ្សែភាពយន្តឯកសារ ពីររឿង (ផលិតដោយលោក **រិទ្ធី ប៉ាន់**) ព្រមទាំងបានស្តាប់សក្ខីកម្មសាក្សីជំនាញមួយចំនួននៅក្នុងអំឡុងពេលនីតិវិធីសវនាការនៃសំណុំរឿង០០១។ សាក្សី **ឌុច** នៅតែរក្សាចម្លើយដែលបានថ្លែងនៅចំពោះមុខមន្ត្រីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលថា គាត់មានការយល់ដឹងច្រើនជាងមុន *"ខ្ញុំពេលនេះ មានការយល់ដឹងច្រើនជាងនៅខែសីហា ឬ ខែធ្នូ កន្លងទៅ។ តាមពិត ពីមុនខ្ញុំបានដឹងបន្តិចបន្តួចពីសំណុំរឿង ក្រោយមក ខ្ញុំយល់កាន់តែច្បាស់ពីរចនាសម្ព័ន្ធនៃរបបនោះ។ ខ្ញុំអាចដឹងពីអ្វីហៅថា គណៈកម្មាធិការការងារជុំវិញមន្ទីរ៨៧០"* ទាក់ទងនឹងអង្គហេតុពាក់ព័ន្ធនឹងការយល់ខុសរបស់គាត់ជាមួយនឹងតួនាទីមន្ទីរស-២១។

## ជំពូកទី ៣ៈ បញ្ហាច្បាប់ និង នីតិវិធី

កិច្ចដំណើរការនៅសប្តាហ៍នេះ បានប្រឈមនឹងបញ្ហានីតិវិធីសំខាន់ៗជាច្រើន ដូចជា ការប្រឈមនឹងការប្រើប្រាស់សិទ្ធិរវាងភាគី និងភាពសាំញ៉ាំនៃការប្រើប្រាស់ឯកសារនៅក្នុងដំណើរការសវនាការ។ សិទ្ធិរបស់ជនជាប់ចោទក្នុងការតទល់ជាមួយសាក្សី ព្រមទាំងការធ្វើតេស្តសាកល្បងលើភាពមិនគួរឲ្យជឿជាក់របស់សាក្សី។ ការជជែកពិភាក្សាអំពីព្រំដែនសិទ្ធិរបស់សាក្សីក្នុងការមិនផ្តល់សក្ខីកម្ម ឬនៅស្ងៀមមិនឆ្លើយតបសំណួរដែលដាក់ពិរុទ្ធភាពលើខ្លួនឯង វិធានការហាមឃាត់ការប្រើប្រាស់ឯកសារដែលធ្វើឡើងដោយតតីយជនដែលមិនមាននៅក្នុងបញ្ជីសំណុំរឿង និងអង្គហេតុដែលមិនស្ថិតនៅក្នុងដីកាបំបែកដំណើរការនីតិវិធី។

### ក. សិទ្ធិប្រឆាំងនឹងការមិនឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង

វិធាន ២៨(១) នៃវិធានផ្ទៃក្នុង ស្តីពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងបានចែងថា ៖

> *សាក្សីអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬ ធ្វើអំណះអំណាងណាមួយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សីនេះ ត្រូវយកមកអនុវត្តនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធី។*

បញ្ហានៃការមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង បានកើតឡើងជាច្រើនលើក ពាក់ព័ន្ធនឹងតួនាទីរបស់សាក្សី **ឌុច** នៅមន្ទីរ ម-១៣ ។ ដូចបានកត់សម្គាល់នៅផ្នែកខាងលើ ការមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងបានក្លាយជាប្រធានបទជជែកពិភាក្សាយ៉ាងក្តៅគគុក។ នៅពេលមេធាវី **ផេស្តមិន** បានចោទសួរសាក្សី **ឌុច** ថាតើគាត់ធ្លាប់បានធ្វើទារុណកម្មដោយផ្ទាល់ទៅលើអ្នកទោសនៅមន្ទីរម-១៣ដែរឬទេ? សាក្សី **ឌុច** បដិសេធមិនឆ្លើយតបនឹងសំណួរ។ មេធាវី **ផេស្តមិន** បានទទួចថា ក្នុងនាមជាសាក្សី គាត់មានកាតព្វកិច្ចត្រូវតែឆ្លើយតបនឹងសំណួរ។ មេធាវីបានបន្តថា សាក្សី **ឌុច** មិនអាចប្រើប្រាស់សិទ្ធិមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងបាន

ទេ ចាប់តាំងពីពេលដែលសំណុំរឿងរបស់គាត់ (សំណុំរឿង០០១) ត្រូវបានតុលាការបានសម្រេចកាត់ទោស និងចេញសាលក្រមស្ថាពរ។ មេធាវី **ម៉ៃខល កាណាវាស** ដែលជាមេធាវីការពារក្ដីឲ្យជនជាប់ចោទ **អៀង សារី** បានគាំទ្រលើការលើកឡើងរបស់មេធាវី **ផេស្គមិន** និងបានដកស្រង់យុត្តិសាស្ត្រនៃសំណុំរឿង *Prosecutor v.* Blagojević និង Jokić នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី *(អាយ.ស៊ី.ធី.វ៉ាយ)* មានខ្លឹមសារថា សាក្សីដែលត្រូវទទួលបានការផ្ដន្ទាទោសជាស្ថាពរហើយនោះ នឹងលែងមានឱកាសប្រើប្រាស់សិទ្ធិមិនឆ្លើយតបប្រឆាំងនឹងការដាក់ពិរុទ្ធភាពលើខ្លួនឯងទៀតទេ ព្រោះថាសាក្សីត្រូវបានការពារដោយគោលការណ៍ *"គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ"* (ne bis in idem)។ សហព្រះរាជអាជ្ញាអន្តរជាតិ **វីល្លៀម ស្មីត** បានឆ្លើយតបនឹងការអះអាងរបស់ក្រុមមេធាវីការពារក្ដី ដោយលើកឡើងថា **ឌុច** មិនត្រូវបានតុលាការធ្វើការចោទប្រកាន់ពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅមន្ទីរម-១៣ទេ ដូច្នេះ គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ ក៏មិនអាចយកមកអនុវត្តបានដែរនៅក្នុងលក្ខខណ្ឌនេះ។

ជាការឆ្លើយតប មេធាវី **ផេស្គមិន** បានលើកទឡ្ហីករណ៍ថា វាមិនមានហេតុផលណាដែល **ឌុច** ត្រូវតុលាការអន្តរជាតិធ្វើការចោទប្រកាន់ពីសកម្មភាពឧក្រិដ្ឋនានា ដែលបានកើតមាននៅមន្ទីរម-១៣។ ចំណែកឯ ព្រះរាជអាជ្ញា **ស្មីត** បានចង្អុលបង្ហាញថា សំណួរនេះគឺមិនមែនជាមូលដ្ឋាននៃការចោទប្រកាន់ ឬការផ្ដន្ទាទោសនោះទេ ប៉ុន្តែ ថាតើសាក្សីអាចនឹងប្រឈមនឹងការចោទប្រកាន់នៅក្នុងតុលាការក្នុងស្រុក។

អង្គជំនុំជម្រះបានគាំទ្រការអះអាងរបស់ភាគីសហព្រះរាជអាជ្ញា និង បានចង្អុលបង្ហាញថា សាក្សី **ឌុច** មានឱកាសអនុវត្តសិទ្ធិរបស់ខ្លួនប្រឆាំងនឹងការផ្ដល់សក្ខីកម្ម ដែលអាចដាក់ពិរុទ្ធភាពប្រឆាំងនឹងខ្លួនឯង ទាក់ទងទៅបញ្ហា ឬអង្គហេតុនានាដែលមិនទាន់ធ្វើការកាត់សេចក្ដីនៅឡើយ។ ទោះបីជាមានសេចក្ដីសម្រេចហើយក៏ដោយ ក៏បញ្ហាដដែលៗនេះបានកើតឡើងវិញ (យ៉ាងតិចពីរដង)។ ប្រធានអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យសួរសំណួរពាក់ព័ន្ធទៅនឹងរបាយការណ៍ស្ដីពីសកម្មភាពឧក្រិដ្ឋកម្មដែលកើតមាននៅមន្ទីរម-១៣ ដែលជាមន្ទីរសន្តិសុខមួយ មិនបានដាក់បញ្ចូលទៅក្នុងបទចោទប្រកាន់ និងបានសម្អាងថា សាក្សីអាចនឹងឆ្លើយដាក់ពិរុទ្ធលើខ្លួនឯង។ ម្យ៉ាងវិញទៀត ការសួរសំណួរផ្សេងៗទាក់ទងនឹងមន្ទីរមួយនេះ គឺមិនមានភាពជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿងបច្ចុប្បន្នឡើយ។ មេធាវី **ផេស្គមិន** បានពោលថា *"ដើម្បីជាកំណត់ត្រា គឺខ្ញុំគិតថាមានតែចម្លើយរបស់សាក្សីទេ ដែលអាចនឹងធ្វើឲ្យគាត់ទទួលបន្ទុកពិរុទ្ធភាព ប៉ុន្តែមិនមែនសំណួរឡើយ"* ។

នៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក **ឌុច** មិនត្រូវបានតុលាការធ្វើការចោទប្រកាន់ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅមន្ទីរម-១៣ទេ ពីព្រោះបទឧក្រិដ្ឋទាំងនោះនៅក្រៅយុត្តាធិការរបស់តុលាការ។ ដូច្នេះ អង្គជំនុំជម្រះត្រូវតែប្រុងប្រយ័ត្នក្នុងការក្រើនរម្លឹកសាក្សី អំពីសិទ្ធិមិនឆ្លើយសំណួរដែលអាចប្រឆាំងនឹងខ្លួនឯង និងប្រុងប្រយ័ត្នលើកិច្ចការពារការប្រើប្រាស់សិទ្ធិរបស់ **ឌុច** ពីហេតុបច្ច័យដែលអាចទាញឲ្យសាក្សីមានជាប់ពាក់ព័ន្ធ ដោយសារតែ អ.វ.ត.ក មិនអាចធានាថា **ឌុច** នឹងមិនត្រូវតុលាការក្នុងស្រុកធ្វើការផ្ដន្ទាទោស។

### ខ. ការដាក់បង្ហាញបញ្ហាបុគ្គលដទៃចំពោះមុខសាក្សី (Putting One's Case before Wit)

ភាពចម្រូងចម្រាសនៅលើរចនាបទ ឬរបៀបសួរដេញដោលសាក្សីពីសំណាក់ក្រុមមេធាវីការពារក្ដីបានបន្តកើតឡើងនៅក្នុងសវនាការនាសប្ដាហ៍នេះ។ ជាពិសេស ការជជែកតតាំងលើភស្តុតាង ថាតើឯកសារអ្វីខ្លះដែលមេធាវីអាចយោង និងប្រើប្រាស់ក្នុងការសួរដេញដោលចំពោះសាក្សី? ខណៈដែលមេធាវីបានទាញ

យកបញ្ហាមួយ ហើយធ្វើការអត្ថាធិប្បាយផ្ទាល់ខ្លួន និងស្នើឲ្យសាក្សីឆ្លើយបញ្ជាក់។ ការទាញយកករណីនេះ ឬការអត្ថាធិប្បាយតទល់នឹងសាក្សី គឺជាបច្ចេកទេសក្នុងការចោទសួរដេញដោលសាក្សី ដែលអនុវត្តនៅក្នុងយុត្តាធិការតុលាការជាច្រើន ពោលគឺការប្រឈមសាក្សីនឹងភស្តុតាងផ្ទុយ (ភស្តុតាងផ្ទុយដែលដាក់បង្ហាញក្នុងបំណងនឹងប្រើប្រាស់ក្នុងតុលាការ) និងការផ្តល់ឱកាសឲ្យសាក្សីធ្វើការពន្យល់បកស្រាយ។[18] ប្រការនេះ គឺជាវិធានបង្ហាញឲ្យដឹងពីភាពត្រឹមត្រូវនៃភស្តុតាងដើមពីសំណុំរឿងរបស់ជនជាតិអង់គ្លេសឈ្មោះ **ប្រោណនី** និង **ឌុន** (Browne VS. Dunn)[19] មេធាវី **កាណាវ៉ាស** បានដកស្រង់អត្ថបទមួយចំនួនពីសំណុំរឿងនេះ ដើម្បីគាំទ្រការលើកទឡ្ហីករណ៍ដែលថា *"វាជាបច្ចេកទេសនៃសួរដេញដោល"*។ យ៉ាងណាមិញ មេធាវីការពារក្តីឲ្យជនជាប់ចោទ **នួន ជា** មានចេតនាបង្ហាញឲ្យឃើញពីភាពមិនគួរឲ្យជឿជាក់របស់សាក្សី **ឌុច**។ មេធាវី **ផេស្តមិន** បានសន្ទនាជាមួយសាក្សីថា ៖

> *តើលោកមិនចាំអក្សរសរសេរដោយដៃរបស់ **នួន ជា** ទេ មែនទេ? ប៉ុន្តែដោយសារតែកាលបរិច្ឆេទដែលបានចុះក្នុងពេលធ្វើចំណារនៅលើឯកសារផ្សេងៗ ហ្នឹងមិនមែនជាអក្សររបស់ **សុន សេន** ទើបលោកសន្មតថា អក្សរសរសេរដោយដៃហ្នឹង ធ្វើឡើងដោយ **នួន ជា** តើអីចឹងមែនទេ?*

ការថ្លែងបែបនេះ បានធ្វើឲ្យសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី **អេលីហ្សាបែត ស៊ីម៉ូនណូហ្សត** ងើបឡើងជំទាស់តវ៉ាថា ការលើកឡើងរបស់មេធាវីការពារក្តីឲ្យជនជាប់លោក **នួន ជា** គឺមិនសមរម្យនោះទេ ដោយសារតែ *"វាមិនមែនជាសំណួរ ប៉ុន្តែជាការសន្និដ្ឋាន ដែលសហភាតារបស់ខ្ញុំចង់ទាញយកពីសាក្សី"*។ មេធាវី **ស៊ីម៉ូនណូហ្សត** បានបន្តថា មេធាវីគួរតែសួរសំណួរចំៗ ជាជាងធ្វើការអត្ថាធិប្បាយ។ គួរកត់សម្គាល់ថា ភាគីសហព្រះរាជអាជ្ញា បានគាំទ្រចំពោះការប្រើប្រាស់បច្ចេកទេសតាំងសំណួរដល់សាក្សី ដោយក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** និង **ខៀវ សំផន** និងបានអះអាងថា វិធីសាស្ត្រនេះត្រូវបានប្រើប្រាស់ដោយតុលាការ *អាយ.ស៊ី.ធី.វ៉ាយ* តុលាការ *អាយ.ស៊ី.ធី.អ័រ* និង តុលាការ *អាយ.ស៊ី.ស៊ី*។ មេធាវី **កាណាវ៉ាស** បានលើកសម្អាងលើការអនុវត្ត ដូចតទៅ ៖

> *ការសាកសួរដេញដោលនេះ គឺធ្វើឡើងបែបក្លាសិក។ ដូច្នេះ វាគឺជានីតិវិធីដែលគេបានប្រើប្រាស់នៅ អាយ.ស៊ី.ធី.វ៉ាយ និងតុលាការផ្សេងៗទៀត។ ការពិតទៅ តុលាការ អាយ.ស៊ី.ធី.វ៉ាយ បានសម្រេចថា មេធាវីប្រឹក្សាត្រូវតែលើកករណីរបស់ខ្លួនមកសាកសួរដេញដោលទៅដល់សាក្សី ពីព្រោះវាជារឿងសំខាន់ណាស់។ ទង្វើបែបនេះ គឺជាអ្វីដែលគេបានបញ្ជាបចូលនៅក្នុងសេចក្តីសម្រេចរបស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ ដោយអតីតចៅក្រមមួយរូប ដែលប្រហែលជាបានទទួលមរណភាពនៅក្នុងអំឡុងសវនាការ មីឡូសឺវិច ។ វាមិនខុសឆ្គងនោះទេ ក្នុងការតាំងសំណួរ ពីព្រោះថា វាបានផ្តល់ឱកាសឲ្យសាក្សីធ្វើការពន្យល់ និងដើម្បីដឹង ថាតើសាក្សីព្រមទទួលយក ឬបដិសេធ? នេះគឺជាវិធីដែលគេធ្វើការសាកសួរតទល់នៅក្នុងដំណើរការនៃការសាកសួរតទល់។*

បន្ទាប់ពីអង្គជំនុំជម្រះបានធ្វើការជំនុំពិភាក្សា ក៏បានចេញសេចក្តីសម្រេចច្រានចោលការជំទាស់របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអនុញ្ញាតឲ្យមេធាវី **ផេស្តមិន** បន្តសួរដេញដោលទៅកាន់ **ឌុច** ។ ទោះបីជាយ៉ាងណា ប្រធានអង្គជំនុំជម្រះ **និល ណុន** បានរម្លឹកដល់ភាគីថា អ.វ.ត.ក នឹងមិនអនុវត្តនីតិវិធីនៃការសួរតទល់ តាមវិធាននៃការតទល់គ្នាដូចដែលបានអនុវត្តនៅតុលាការអន្តរជាតិ *អាយ.ស៊ី.ធី.អ័រ* និង *អាយ.ស៊ី.ធី.*

*ភ័យ*។ ប្រធានអង្គជំនុំជម្រះក៏បានណែនាំមេធាវី **ផេស្គមិន** ឲ្យរៀបចំសំណួរឲ្យខ្លី និងសាមញ្ញងាយយល់។ ទោះបីជាយ៉ាងណា មេធាវីរូបនេះនៅតែបន្តសួរសំណួរបែបអត្ថាធិប្បាយ ដែលធ្វើឲ្យមានការជំទាស់ជាបន្តបន្ទាប់ពីភាគីដទៃ។ ជាលទ្ធផល អង្គជំនុំជម្រះបានណែនាំមិនឲ្យសាក្សី **ឌុច** ឆ្លើយសំណួរទាំងនោះ។

## គ. នីតិវិធីនៃការដាក់បង្ហាញឯកសារចំពោះសាក្សី

សប្តាហ៍នេះ តុលាការបានចំណាយពេលវេលាយ៉ាងច្រើន ក្នុងការជជែកពិភាក្សាពីនីតិវិធីសម្រាប់ការប្រើប្រាស់ឯកសារក្នុងការសួរដេញដោលសាក្សី។ អង្គជំនុំជម្រះជាញឹកញាប់បានធ្វើការក្រើនរម្លឹកភាគីអំពីនីតិវិធីដែលបានបង្កើតឡើងកាលពីសប្តាហ៍មុនៗ។ អង្គជំនុំជម្រះក៏បានចេញសេចក្តីសម្រេច ដើម្បីដោះស្រាយបញ្ហាថ្មីៗទាក់ទងនឹងការដាក់បង្ហាញឯកសារ។

### *គ.១. ការណែនាំពីរបៀបដាក់បង្ហាញឯកសារចំពោះសាក្សី*

អង្គជំនុំជម្រះ បានបន្តធ្វើការរម្លឹកដល់មេធាវីការពារក្តីពីនីតិវិធីក្នុងការដាក់បង្ហាញឯកសារភស្តុតាងដូចខាងក្រោម ៖

- ភាគីនីមួយៗត្រូវតែអានឯកសារឲ្យឮៗ និងលេខយោងនៃភស្តុតាង (ERN)[20] ជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ដើម្បីឲ្យអង្គជំនុំជម្រះ និងភាគីដទៃទៀត អាចងាយស្រួលរកឯកសារដែលនឹងត្រូវបង្ហាញចំពោះសាក្សី។
- ឯកសារដែលត្រូវបង្ហាញលើអេក្រង់កំព្យូទ័រ នឹងត្រូវប្រគល់ជូនសាក្សីនូវឯកសារថតចម្លងមួយច្បាប់ ដើម្បីឲ្យសាក្សីអាចអានផ្ទៀងផ្ទាត់។
- មុនសួរសំណួរលើឯកសារដាក់បង្ហាញទាំងនេះ ជាបឋម ភាគីត្រូវសួរសាក្សី ថាតើគាត់ធ្លាប់បានឃើញ ស្គាល់ ឬចំណាំឯកសារទាំងនេះដែរឬទេ?
- ប្រសិនបើសាក្សីធ្លាប់បានឃើញឯកសារទាំងនេះ ភាគីអាចសួរសំណួរទាក់ទងនឹងឯកសារនោះបាន។ សាក្សីអាចចាត់ទុកថា “ធ្លាប់បានឃើញឯកសារ” ប្រសិនបើសាក្សីបានឃើញឯកសារនោះ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ ពោលគឺក្រោយឆ្នាំ១៩៧៩ ឬ បានឃើញក្នុងដំណាក់កាលស៊ើបអង្កេតនៅការិយាល័យសហចៅក្រមស៊ើបអង្កេត។
- ប្រសិនបើសាក្សីមិនបានឃើញឯកសារនេះ ត្រូវដកឯកសារនេះចេញពីសាក្សី និងមិនត្រូវចាក់បង្ហាញនៅលើអេក្រង់កំព្យូទ័រផងដែរ។ ភាគីមិនត្រូវសួរដេញដោលសាក្សីនូវសំណួរដោយផ្អែកលើខ្លឹមសារនៃឯកសារឡើយ។ ទោះបីជាយ៉ាងណា ភាគីនៅតែអាចសួរសំណួរជាលក្ខណៈទូទៅពាក់ព័ន្ធនឹងឯកសារនេះ។

ទោះបីជាមានការរម្លឹកពីអង្គជំនុំជម្រះក៏ដោយ ក៏ភាគីមិនបានគោរពតាមនីតិវិធីនោះទេ ដែលធ្វើឲ្យបញ្ហាដដែលៗកើតឡើងជាច្រើនលើកនៅក្នុងពេលសួរដេញដោលសាក្សី។

### *គ.២. សេចក្តីត្រូវការក្នុងការប្រើប្រាស់ឯកសារ*

អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចថា រាល់ឯកសារដែលត្រូវបានដាក់បង្ហាញនៅក្នុង

តុលាការ គឺត្រូវតែជាឯកសារដែលបានយកចេញពីបញ្ជីសំណុំរឿង និងបានដាក់បញ្ចូលទៅក្នុងបញ្ជីឯកសាររបស់ភាគីនីមួយៗ ដោយធ្វើការចង្អុលបង្ហាញពីចរិតលក្ខណៈនៃឯកសារភស្តុតាង ដែលពួកគេមានបំណងចង់ប្រើប្រាស់នៅក្នុងសវនាការសាធារណៈ។ នៅក្នុងពេលសួរដេញដោលនៅថ្ងៃពុធ មេធាវី **ផេស្តមិន** មានចេតនាចង់បង្ហាញចម្លើយសារភាពរបស់ **ឌុច** ដែលបានថ្លែងក្នុងសវនាការសំណុំរឿង០០១ ប៉ុន្តែឯកសារនេះមិនទាន់បានដាក់បញ្ចូលទៅក្នុងបញ្ជីសំណុំឯកសារនៅឡើយ។ មេធាវី **ផេស្តមិន** បានតវ៉ាថា គាត់មិនស្នើសុំដាក់ឯកសារជាផ្លូវការថាជាឯកសារភស្តុតាងទេ ព្រោះគាត់ចង់ត្រឹមតែប្រើប្រាស់ក្នុងគោលបំណងសួរផ្ទុយ ឬសុំឲ្យមានការឆ្លើយបញ្ជាក់ពីសាក្សី **ឌុច** ចំពោះសេចក្តីថ្លែងមួយចំនួនដែលសាក្សីបានថ្លែងក្នុងឯកសារនោះ។ ទោះបីជាភាគីសហព្រះរាជអាជ្ញាបានតតាំងថា ក្រុមមេធាវីការពារក្តីមានសិទ្ធិធ្វើតេស្តសាកល្បងលើភាពអាចទុកចិត្តបាន និងភាពគួរឲ្យជឿជាក់លើសាក្សីក៏ដោយ ក៏សហព្រះរាជអាជ្ញាបានបន្តលើកឡើងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ស្តីពីការប្រើប្រាស់ឯកសារ ដែលគ្រប់ភាគីត្រូវតែអនុវត្តតាម។ ព្រះរាជអាជ្ញា **ស្មីត** បានពន្យល់ថា យោងតាមការពិភាក្សាជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះនៅក្នុងកិច្ចប្រជុំស្តីពីការគ្រប់គ្រងសវនាការ បានកត់សម្គាល់ថា គោលបំណងនៃការប្រើប្រាស់ឯកសាររបស់ភាគី គឺដើម្បីតទល់ទៅនឹងភាពអាចទុកចិត្តបានរបស់សាក្សី ប៉ុន្តែតម្រូវឲ្យមានការជូនដំណឹងពីឯកសារទាំងនេះដល់ភាគីនានាជាមុន។ ព្រះរាជអាជ្ញាបានគូសបញ្ជាក់ជាបន្តថា ភាគីដែលមានបំណងចង់ប្រើប្រាស់ឯកសារណាមួយនោះ ត្រូវតែជូនដំណឹងយ៉ាងតិច ២៤ម៉ោង មុនសវនាការចាប់ផ្តើម ជាពិសេស ក្រុមមេធាវីការពារក្តីគួរបានដឹងជាមុន ថាតើឯកសារណាមួយដែលក្រុមខ្លួនចង់ប្រើប្រាស់ដើម្បីធ្វើការតទល់នឹងសាក្សី។

សូម្បីតែអង្គជំនុំជម្រះក៏ទទួលស្គាល់សិទ្ធិរបស់ភាគីការពារក្តីក្នុងការធ្វើតេស្តសាកល្បងពីភាពអាចទុកចិត្តបាននៃសាក្សីណាម្នាក់ ដូចមានថ្លែងនៅក្នុងសេចក្តីសម្រេចនេះថា ៖

> *នេះជាសិទ្ធិរបស់មេធាវី ប៉ុន្តែសិទ្ធិនេះត្រូវតែអនុវត្តឲ្យបានត្រឹមត្រូវតាមវិធានផ្ទៃក្នុង និងបទបញ្ញត្តិដែលពាក់ព័ន្ធនឹងការសួរដេញដោលចំពោះសាក្សី។ ទីពីរ ឯកសារដែលមេធាវីយកមកដេញដោល ត្រូវតែជាឯកសារដែលមាននៅក្នុងសំណុំរឿង០០២។ ទីបី ឯកសារដែលមេធាវីនឹងយកមកប្រើប្រាស់នៅក្នុងការដេញដោល ត្រូវអនុវត្តទៅតាមការណែនាំរបស់អង្គជំនុំជម្រះមានន័យថា ត្រូវជូនដំណឹងមកភាគីឲ្យបានដឹងមុនយ៉ាងតិច ២៤ម៉ោង។*

មេធាវី **ផេស្តមិន** យល់ព្រមអនុវត្តតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ និងប្រកាសថា ក្រុមខ្លួននឹងផ្តល់បញ្ជីឯកសារជូនអង្គជំនុំជម្រះ និងភាគីនានា នៅពេលដែលក្រុមខ្លួននឹងប្រើប្រាស់សួរដេញដោលសាក្សីនៅពេលអនាគត។ ទោះបីជាយ៉ាងណា លោកមេធាវីបានសង្កត់ធ្ងន់ថា អង្គជំនុំជម្រះគួរតែអនុញ្ញាតឲ្យមេធាវីប្រើប្រាស់ឯកសារមួយចំនួនដែលមិនទាន់ដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារតុលាការ ព្រោះថា ក៏ប៉ុន្តែឯកសារទាំងនោះមានសារៈសំខាន់ក្នុងការស្វែងរកការពិត។ លោកមេធាវីបានបន្តថា ឯកសារទាំងនោះអាចនឹងដាក់បញ្ចូលទៅក្នុងបញ្ជីឯកសារតុលាការ ក្រោយពេលបញ្ចប់ការសួរដេញដោល។

ទោះបីជាយ៉ាងណា បញ្ហាដូចគ្នានេះបានលេចឡើងជាថ្មីម្តងទៀត នៅពេលដែលមេធាវី **ផេស្តមិន** បានព្យាយាមបង្ហាញខ្សែភាពយន្តឯកសារខ្នាតខ្លីមួយ ដែលមានចំណងជើងថា *"ឌុច គឺជាប្រធានយមបាល"* (Duch, Master of the forges of hell)[21] ដែលនិពន្ធដោយលោក **ប៉ាន់ រិទ្ធី**។ ភាពយន្តឯកសារមួយនេះមានបទសម្ភាសន៍ **ឌុច** ជាច្រើន។ ភាគីសហព្រះរាជអាជ្ញាបានជំទាស់ ដោយបានលើកឡើងថា មេធាវីការពារ

ក្ដីឲ្យជនជាប់ចោទ **នួន ជា** មិនទាន់បានដាក់បញ្ចូលខ្សែភាពយន្តនេះនៅក្នុងបញ្ជីឯកសារ ដែលពួកគេមានគោលបំណងចង់ដាក់បង្ហាញសាក្សីទេ។ ព្រះរាជអាជ្ញា **ស្មីត** បានបន្តលើកទឡ្ហីករណ៍ថា ខ្សែភាពយន្តនេះមិនទាន់មានក្នុងបញ្ជីសំណុំរឿងនៅឡើយទេ ដូចនេះសន្មតថា មេធាវីមិនបានបំពេញលក្ខខណ្ឌដែលកំណត់ក្នុងវិធាន ៨៧(៤)។ ភាគីសហព្រះរាជអាជ្ញាស្នើថា ខ្សែភាពយន្តនេះគួរដាក់បង្ហាញនៅពេលក្រោយ រហូតទាល់តែភាគីការពារក្ដីបានដាក់ខ្សែភាពយន្តឯកសារនេះដល់ភាគីនានា ឲ្យបានសិក្សាជាមុន ស្របតាមវិធាន ៨៧(៤) ដែលកំណត់ថា *"គ្រប់ភាគីដែលបានស្នើសុំប្រើប្រាស់ឯកសារ ត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឲ្យច្បាស់លាស់... ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្ម ឬភស្តុតាងដែលស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្ដើមជំនុំជម្រះ"*។ ព្រះរាជអាជ្ញា **ស្មីត** បានរម្លឹកភាគីថា សវនាការនេះ គឺជាសវនាការខ្នាតអន្តរជាតិ ប្រសិនបើភាគីបង្ហាញឯកសារថ្មីដែលមិនពាក់ព័ន្ធ ដូច្នេះ មិនមានផលល្អដល់កិច្ចគ្រប់គ្រងសវនាការទេ។ គួររម្លឹកថា សវនាការមុនមួយថ្ងៃ មេធាវី **ផេស្តមិន** បានរក្សាជំហរថា គាត់មិនមានបំណងដាក់បញ្ចូលឯកសារក្នុងបញ្ជីសំណុំរឿងទេ ប៉ុន្តែគ្រាន់តែចង់ដឹងពីភាពស្មោះត្រង់របស់សាក្សី **ឌុច** ប៉ុណ្ណោះ។

អង្គជំនុំជម្រះសាលាដំបូង បានគាំទ្រការជំទាស់របស់ភាគីសហព្រះរាជអាជ្ញា និងបង្គាប់មិនឲ្យចាក់បញ្ចាំងខ្សែភាពយន្តនេះទេ។ លោកស្រីចៅក្រម **ស៊ីលវៀ ខាតវ៉ាយថ៍** បានបញ្ជាក់បន្ថែមថា ប្រសិនបើមេធាវីការពារក្ដីចង់បង្ហាញខ្សែភាពយន្តមួយនេះ មេធាវីត្រូវតែធ្វើការស្នើសុំជាផ្លូវការ ផ្អែកតាមវិធាន ៨៧(៤)។

### *គ.៣. ឯកសារដាក់បង្ហាញសាក្សីត្រូវតែជាឯកសារពេញលេញ*

មេធាវី **ផេស្តមិន** មានបំណងធ្វើតេស្តសាកល្បងពីសមត្ថភាពចងចាំរបស់សាក្សី **ឌុច** ថាតើគាត់អាចចំណាំឯកសារដែលគ្មានចំណារលើនោះដែរឬទេ។ មេធាវីបានបិទចំណារដែលមាននៅលើចម្លើយសារភាព (ចម្លើយសារភាពនេះ **ឌុច** បានធ្វើជូនថ្នាក់លើហើយ) និងចាប់ផ្ដើមសួរសំណួរទៅកាន់សាក្សី។ ការធ្វើបែបនេះ បានធ្វើឲ្យភាគីសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ងើបឡើងជំទាស់ដោយហេតុផលថា មេធាវីការពារក្ដីគួរតែបង្ហាញឯកសារទាំងស្រុង និងមិនត្រូវបិទបាំងផ្នែកណាមួយទេ។ អង្គជំនុំជម្រះបានគាំទ្រការជំទាស់របស់ភាគីទាំងពីរ និងបានណែនាំដល់មេធាវី **ផេស្តមិន** ឲ្យដាក់បង្ហាញឯកសារទាំងស្រុងដល់សាក្សី **ឌុច** ដើម្បីឲ្យគាត់មើលបានពេញលេញ។

### *គ.៤. សាក្សីមិនមានសិទ្ធិផ្ដល់មតិយោបល់លើចម្លើយរបស់សាក្សីដទៃ*

នៅក្នុងសវនាការមុនៗ អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចថា ការស្នើឲ្យសាក្សីផ្ដល់មតិយោបល់លើចម្លើយរបស់សាក្សីដទៃទៀត គឺមិនអនុញ្ញាតទេ។ សវនាការនៅក្នុងសប្ដាហ៍នេះ មេធាវី **ផេស្តមិន** មានចេតនាតទល់សាក្សី **ឌុច** ជាមួយនឹងចម្លើយរបស់អតីតកម្មាភិបាល **ប្រាក់ ខន** ដែលជាអ្នកសួរចម្លើយនៅមន្ទីរ ស-២១។ ភាគីសហព្រះរាជអាជ្ញាបានជំទាស់ និងបានលើកឡើងពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងបញ្ហានេះ។ មេធាវី **ផេស្តមិន** បានតវ៉ាថា សាក្សី **ឌុច** អាចនៅចាំពីចម្លើយរបស់កម្មាភិបាល **ប្រាក់ ខន** ព្រោះឯកសារនេះបានដាក់បង្ហាញរួចហើយនៅក្នុងដំណើរការសំណុំរឿង០០១ និងអះអាងថា ក្រុមរបស់ខ្លួនគួរតែមានសិទ្ធិក្នុងការតទល់សាក្សីដោយប្រើប្រាស់ចម្លើយរបស់បុគ្គលផ្សេង ដែលបានផ្ដល់ព័ត៌មានផ្ទុយពី

សក្ខីកម្មរបស់ **ឌុច** ។ លោកមេធាវីបានបន្ថែមថា ដោយសារតែ **ប្រាក់ ខន** ដែលជាអតីតអ្នកសួរចម្លើយមិនមានឈ្មោះនៅក្នុងបញ្ជីសាក្សីនៃសំណុំរឿង០០២ អង្គជំនុំជម្រះសាលាដំបូង មិនអាចសួរដេញដោលសាក្សីលើបញ្ហាទាំងអស់នេះបានទេ។

អង្គជំនុំជម្រះបានសម្រេចថា *"អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យមេធាវីការពារក្តីយកចម្លើយសាក្សីផ្សេងយកមកដកស្រង់ មកសួរដេញដោលចំពោះសាក្សីផ្សេងទេ។ មេធាវីអាចចោទសំណួរជាទូទៅដោយផ្អែកលើខ្លឹមសារដែលខ្លួនបានយល់ដឹង តាមការអាន និងមើលឯកសារនោះ"* ។

មេធាវី **ផេស្តមិន** បានស្នើសុំឲ្យអង្គជំនុំជម្រះបំភ្លឺ ថាតើសេចក្តីសម្រេចនេះនឹងត្រូវអនុវត្តចំពោះសាក្សីទាំងអស់ឬយ៉ាងណា? (ឧ.សាក្សីមួយចំនួនដែលនឹងមិនបានចូលខ្លួនមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ) ឬក៏សេចក្តីសម្រេចនេះមានអានុភាព ចំពោះតែសាក្សីដែលចូលមកបំភ្លឺនៅក្នុងតុលាការ។ ទោះបីជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងមិនបានឆ្លើយតបនឹងសំណួររបស់មេធាវី **ផេស្តមិន** ។ ចំណុចនេះ គឺជាភាពត្រឹមត្រូវ ប៉ុន្តែមេធាវីមិនទទួលបានចម្លើយទេ។

### *គ.៥. សាក្សីមិនអាចផ្តល់មតិយោបល់លើបទសម្ភាសន៍ដែលធ្វើដោយភាគីទីបី*

មេធាវី **ផេស្តមិន** ក៏មានបំណងដាក់បង្ហាញបទសម្ភាសន៍មួយដល់សាក្សី **ឌុច** ដែលតាមឲ្យដឹងថា បទសម្ភាសន៍នោះធ្វើឡើងដោយលោក **ឆិន យៀវនិន** ជាមួយឯកឧត្តម **ហេង សំរិន** កាលពីឆ្នាំ១៩៩១ ដែលខ្លឹមសារនៅក្នុងបទសម្ភាសន៍នោះ គឺបាននិយាយលម្អិត អំពីតួនាទីរបស់គាត់ក្នុងការវាយដណ្តើមយកទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥។ យោងតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះមុនៗ ភាគីសហព្រះរាជអាជ្ញាបានជំទាស់នឹងការដាក់បង្ហាញឯកសារនេះទៅសាក្សី និងបានថ្លែងថា សហព្រះរាជអាជ្ញាមិនបានយល់ដឹងពីខ្លឹមសារនៅក្នុងឯកសារនេះទេ។ ព្រះរាជអាជ្ញា **ស្មីត** ក៏បានស្នើថា តាមវិធីផ្សេងទៀត គឺថា មេធាវី **ផេស្តមិន** អាចចោទសួរអំពីប្រធានបទទូទៅពាក់ព័ន្ធនឹងឯកសារនេះ។ អង្គជំនុំជម្រះ បានយល់ស្របនឹងការជំទាស់របស់សហព្រះរាជអាជ្ញា និងបានណែនាំមេធាវី **ផេស្តមិន** ឲ្យសួរតែសំណួរទូទៅ និងមិនត្រូវយោងផ្អែកជាក់លាក់ពីបទសម្ភាសន៍នេះឡើយ។ ទោះបីជាយ៉ាងណា នៅពេលដែលបន្តសំណួររបស់ខ្លួន មេធាវីរូបនេះនៅតែយោងទៅលើបទសម្ភាសន៍របស់ឯកឧត្តម **ហេង សំរិន** ដែលជាមូលហេតុនាំឲ្យភាគីសហព្រះរាជអាជ្ញាលើកការជំទាស់ពីរដងទៀត។ អង្គជំនុំជម្រះសាលាដំបូង បានក្រើនរម្លឹកមេធាវីការពារក្តីឲ្យព្យាយាមប្រតិបត្តិតាមការណែនាំរបស់អង្គជំនុំជម្រះ។

### *គ.៦. សាក្សីមិនអាចផ្តល់យោបល់លើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ*

ជាថ្មីម្តងទៀត ក្នុងគោលបំណងដើម្បីដេញដោលពីភាពស្មោះត្រង់ និងភាពគួរឲ្យជឿជាក់របស់ **ឌុច** មេធាវី **ផេស្តមិន** បានស្នើឲ្យ **ឌុច** ផ្តល់យោបល់លើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះសាលក្រមនៃសំណុំរឿង០០១។ នៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា **ឌុច** "មិនគួរឲ្យជឿជាក់ទេ" នៅពេល **ឌុច** អះអាងថា កម្មាភិបាល **សុន សេន** បានប្រគល់សំបុត្រមួយចំនួនឲ្យទៅគាត់ផ្ទាល់ដៃ។[22]

ព្រះរាជអាជ្ញាបានតតាំងថា ករណីនេះមិនសមស្របសម្រាប់ **ឌុច** ផ្តល់មតិយោបល់លើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ មេធាវី **កាណាវាស** មិនឯកភាពតាមការតវ៉ានេះ ដោយថ្លែងថា នេះគឺជា

ឱកាសសម្រាប់សាក្សីក្នុងការថ្លែងមតិយោបល់របស់ខ្លួន នៅពេលដែលគាត់ត្រូវបានគេរកឃើញថា មិនមានភាពស្មោះត្រង់នៅក្នុងការអះអាងកន្លងមក ដែលគាត់ថ្លែងថា នឹងពោលតែពាក្យពិត ១០០% ដល់តុលាការ ប៉ុន្តែសាក្សីក៏មានភាពស្រពិចស្រពិលផងដែរ។

បន្ទាប់ពីបានស្តាប់ជំហររបស់ភាគីរៀងៗខ្លួន អង្គជំនុំជម្រះ បានសម្រេចគាំទ្រការជំទាស់របស់ភាគីសហព្រះរាជអាជ្ញា និងបានណែនាំសាក្សីមិនឲ្យឆ្លើយតបនឹងសំណួររបស់មេធាវី **ផេស្តមិន** ។ លោកស្រីចៅក្រម **ខាតរ៉ាយច៍** បានបន្ថែមថា វាមិនមានប្រយោជន៍អ្វីដែលភាគីស្នើឲ្យសាក្សីធ្វើអត្ថាធិប្បាយលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទេ *"មិនតម្រូវឲ្យសាក្សីរូបនេះធ្វើការផ្តល់មតិយោបល់មកដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះទេ"*។

### ឃ. ឯកសារដែលភ្ជាប់ជាមួយកំណត់ត្រាកិច្ចសម្ភាសន៍របស់សាក្សី ត្រូវចាត់ទុកថា បានដាក់ចំពោះមុខអង្គជំនុំជម្រះ

កាលពីថ្ងៃច័ន្ទ ក្នុងអំឡុងពេលនៃការពិភាក្សាស្តីពីការបែងចែកពេលវេលាសម្រាប់ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **ខៀវ សំផន** មេធាវី **អាកទូរ វ៉ែកគេន** បានស្នើសួរអង្គជំនុំជម្រះសាលាដំបូង ថាតើនៅពេលដល់ដំណាក់កាលជជែកពិភាក្សារបស់អង្គជំនុំជម្រះ តើតុលាការនឹងពិចារណាតែលើសក្ខីកម្ម និងឯកសារទាំងឡាយ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះអំឡុងពេលសវនាការ ឬក៏ទទួលយកភស្តុតាងទាំងអស់នៅក្នុងដំណាក់កាលស៊ើបអង្កេតនៃសំណុំរឿង០០២។ យោងតាមមេធាវី **វ៉ែកគេន** បានឲ្យដឹងថា មូលហេតុដែលពួកគេចង់ដឹង ពីព្រោះពួកគេចង់ធ្វើការកំណត់ពេលវេលាក្នុងការសួរដេញដោលសាក្សី **ឌុច** ថាតើបទសម្ភាសន៍នោះមានទំហំប៉ុណ្ណា ៦៥បទសម្ភាសន៍ ដែលសាក្សីបានធ្វើជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត។ ការឆ្លើយតបរបស់ភាគីសហព្រះរាជអាជ្ញា ដោយមានការគាំទ្រពីសំណាក់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺរាល់ចម្លើយសាក្សីនៅគ្រប់ដំណាក់កាលទាំងអស់ បូករួមនឹងសក្ខីកម្មដែលបានធ្វើមុនៗ ត្រូវយកមកពិចារណានៅក្នុងកិច្ចពិភាក្សារបស់អង្គជំនុំជម្រះ។ ព្រះរាជអាជ្ញា **ស្មីត** បានថ្លែងថា អនុលោមតាមការអនុវត្តតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គឺថា ទាំងសក្ខីកម្ម និងសេចក្តីថ្លែងការណ៍របស់សាក្សី គួរតែត្រូវបានយកមកពិចារណា។

ដើម្បីឆ្លើយតប ប្រធានអង្គជំនុំជម្រះ និងលោកចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** បានយោងវិធានផ្ទៃក្នុង ៨៧(៣) ដែលបានចែងថា អង្គជំនុំជម្រះនឹងពិចារណាគ្រប់ឯកសារដែលដាក់នៅចំពោះមុខ។ ចៅក្រម **ឡាវែន៍** បានថ្លែងថា ៖

> *យើងនឹងមិនប្រើប្រាស់តែទៅលើឯកសារដែលបានអានទេ (ក្នុងបន្ទប់សវនាការ)។ គឺមានន័យថា ឯកសារទាំងអស់ ទាំងស្រុងតែម្តងនឹងត្រូវយកមកពិចារណា មិនមែនត្រឹមតែផ្នែកដែលត្រូវបានអាននោះទេ។ នេះជាអ្វីដែលយើងបានបញ្ជាក់រួចមកហើយ នៅពេលដែលសាក្សីមកផ្តល់សក្ខីកម្មនោះ គឺថា អ្វីដែលគាត់បានផ្តល់ពីមុនមក គឺបានចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។ ត្រង់នេះមានន័យយ៉ាងម៉េច? មានន័យថា ភាគីទាំងអស់ ប្រសិនបើត្រូវការ ពួកគាត់មានឱកាសក្នុងការផ្អែក ឬយោងលើឯកសារទាំងអស់នោះនៅក្នុងការសួរសំណួរ ។ ប្រសិនបើភាគីចង់ប្រើប្រាស់ ភាគីអាចប្រើបាន។*

នៅថ្ងៃបន្ទាប់ ព្រះរាជអាជ្ញា **ស្មឺត** បានស្នើសុំឲ្យមានការពន្យល់ ថាតើសេចក្ដីសម្រេចនេះ អាចជះឥទ្ធិពលដល់អនុស្សរណៈលេខ អ៊ី១៧២/៥ (E172/5) ឃ្លាទី៤ ដូចម្ដេចដែរ។ ឃ្លាទី៤ បានចែងថា ៖

> *ឯកសារទាំងអស់ដែលបានភ្ជាប់ទៅនឹងកំណត់ត្រានៃបទសម្ភាសន៍របស់សាក្សី ឬ បទសម្ភាសន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានផ្ដល់សក្ខីកម្មដល់បច្ចុប្បន្ននេះ ហើយសាក្សីទាំងនោះ បូករួមទាំងដើមបណ្ដឹងរដ្ឋប្បវេណី និង សាក្សីជំនាញ ដែលឈ្មោះរបស់ពួកគាត់ត្រូវបានគេចង្អុលបង្ហាញនៅក្នុងអនុស្សរណៈលេខ អ៊ី១៧២ សម្រាប់សវនាការវគ្គក្រោយទៀត អ្នកទាំងនោះនឹងត្រូវបានចាត់ទុកថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះជាមួយនឹងសក្ខីកម្មរបស់បុគ្គលនោះ លើកលែងតែមានការជំទាស់ពីភាគីក្នុងអំឡុងសក្ខីកម្មនេះ ។*[23]

ព្រះរាជអាជ្ញា **ស្មឺត** បានស្នើឲ្យមានការបញ្ជាក់ស្រដៀងគ្នាលើឯកសារមួយចំនួនទៀត ដែលមិនរាប់បញ្ចូលទៅក្នុងការជជែកពិភាក្សាកាលពីថ្ងៃទី១២-១៥ ខែមីនា ឆ្នាំ២០១២ រួមមាន ឧបសម្ព័ន្ធ អេ១២ (A12) ពាក់ព័ន្ធនឹងកំណត់ហេតុយកចម្លើយរបស់សាក្សីម្នាក់ និង ឧបសម្ព័ន្ធ អេ១៣ (A13) ជាសំណុំពាក្យបណ្ដឹងនៅក្នុងសេចក្ដីយោងទៅកថាខណ្ឌ ៧ នៃអនុស្សរណៈ ដែលចែងថា សេចក្ដីណែនាំបន្ថែមលើឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ អេ១២ និង អេ១៣ គួរតែដាក់នៅក្នុងពេលវេលាសមស្រប បន្ទាប់ពីមានការចេញសេចក្ដីសម្រេចលើបញ្ហាដែលកើតឡើង។ ភាគីដទៃទៀត បានសម្ដែងការគាំទ្រចំពោះភាគីព្រះរាជអាជ្ញាដែលស្នើសុំឲ្យមានការបំភ្លឺបន្ថែមឲ្យច្បាស់ពីអង្គជំនុំជម្រះ។ មេធាវីនាំមុខ **ស៊ីម៉ុនណូហ្សត** ដែលជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី បានធ្វើការកត់សម្គាល់ថា ៖

> *ខ្ញុំគិតថា វាជាការសំខាន់ណាស់ដែលអង្គជំនុំជម្រះត្រូវបញ្ជាក់ថា ត្រូវតែមានការបែងចែកច្បាស់លាស់រវាងកំណត់ហេតុស្ដាប់ចម្លើយ និង សេចក្ដីប្រកាសផ្សេងៗទៀតជាលាយលក្ខណ៍អក្សរដែលបុគ្គលណាម្នាក់បានធ្វើឡើង។ គឺថា រាល់សេចក្ដីប្រកាសពុំមានតម្លៃជាច្បាប់ ដូចកំណត់ហេតុស្ដាប់ចម្លើយនោះទេ ព្រោះកំណត់ហេតុស្ដាប់ចម្លើយនេះជាភស្តុតាងនៅក្នុងសំណុំរឿង។*

ដោយឡែក ចំពោះតម្លៃ និងទម្ងន់នៃភស្តុតាង គឺអាស្រ័យទៅលើអង្គជំនុំជម្រះជាអ្នកសម្រេចចុងក្រោយ។

បន្ទាប់ពីបញ្ចប់កិច្ចពិភាក្សា អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា នឹងចេញសេចក្ដីសម្រេចលើការជំទាស់ទាំងនេះនៅក្នុងពេលវេលាសមស្រប។ ទោះបីជាយ៉ាងណា អង្គជំនុំជម្រះបានប្រកាសថា រាល់កំណត់ត្រាដៃ ដែលធ្វើក្នុងពេលផ្ដល់បទសម្ភាសន៍នៅការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០១ និង សំណុំរឿង០០២ ត្រូវចាត់ទុកថា បានដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងជាផ្លូវការ ដោយមិនគិត ថាតើបទសម្ភាសន៍ទាំងនេះបាន ឬមិនបានជជែកពិភាក្សាក្នុងតុលាការ។ សេចក្ដីប្រកាសនេះ ក៏បានអនុញ្ញាតឲ្យភាគីអាចប្រើប្រាស់ប្រតិចារឹកនៃសំណុំរឿង០០១ ក្នុងលក្ខខណ្ឌថា *"ភាគីត្រូវតែបញ្ជាក់ឲ្យបានច្បាស់ពីផ្នែកទាំងឡាយ ដែលខ្លួនមានបំណងប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការសួរសំណួរ"* ។ លើសពីនេះ អង្គជំនុំជម្រះបានតម្កល់ខ្លឹមសារទាំងអស់នៅក្នុងកថាខណ្ឌទី៤ នៃអនុស្សរណៈលេខអ៊ី១៧២/៥។

## ង.	ការទទួលយកឯកសារ និង យថាភាពនៃឯកសារ ៖ សិទ្ធិសាក្សីក្នុងការតទល់នឹងឯកសារនានា

មេធាវី **ផេស្គមិន** បានដាក់បង្ហាញ **ឌុច** នូវកំណត់ត្រានៃកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹងអ្នកសារព័ត៌មានលោក **គ្រីស្តូហ្វ ប៉េស៊ូ** ដែលបានដកស្រង់ពីដីកាដំណោះស្រាយ ឯកសារនេះចាត់ទុកថាបានដាក់ចំពោះមុខអង្គជំនុំជម្រះ។ ជំនួសការអានឯកសារជូនអង្គជំនុំជម្រះ មេធាវី **ផេស្គមិន** បានថ្លែងទៅ **ឌុច** ដោយចំពោះថា ៖ ការពិត **ឌុច** បានប្រាប់ចោលមិនទទួលស្គាល់ឯកសារនេះ តាំងពីមានការដាក់បង្ហាញជាលើកដំបូង ដោយសារតែបញ្ហាយថាភាពនៃឯកសារ ព្រោះអំឡុងពេលនោះ ភាគីមិនផ្តល់ឯកសារច្បាប់ដើមជូនអង្គជំនុំជម្រះ ចំណែកឯ ខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍ក៏មានភាពមិនច្បាស់លាស់។

លោកស្រីចៅក្រម **ស៊ីលវៀ ខាតវ៉ាយថ៍** បានគូសបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងមិនបានចេញសេចក្តីសម្រេចលើបញ្ហាស្តីពីយថាភាពនៃឯកសារទេ ហើយកំណត់ត្រាផ្សេងៗនៃកិច្ចសម្ភាសន៍ជាមួយ **ឌុច** ក្នុងសំណុំរឿង០០១ ក៏មិនមានតម្លៃជាភស្តុតាងដែរ។ លោកស្រីបានបន្ថែមថា ខណៈដែលមេធាវីការពារក្តីអាចនឹងសួរសំណួរផ្សេងៗផ្អែកទៅលើឯកសារទាំងនេះ សាក្សី **ឌុច** ក៏មានឱកាសធ្វើការជំទាស់តវ៉ានឹងឯកសារទាំងនោះ ទោះបីតាមវិធីណាក៏ដោយដែលសាក្សីយល់ថាសមស្របសម្រាប់ខ្លួន។ ក្រៅពីនេះ សាក្សី **ឌុច** បានបដិសេធជាថ្មី មិនធ្វើតាមការស្នើរបស់មេធាវី **ផេស្គមិន** ដែលសុំឲ្យគាត់ជួយអានសម្រង់អត្ថបទមួយ។ សាក្សី **ឌុច** បាននិយាយឲ្យដឹងថា *"ខ្ញុំមកនេះ មកស្តាប់ចៅក្រម មិនមែនមកស្តាប់អ្នកឯងទេ"* ។[24] លោកស្រី **ខាតវ៉ាយថ៍** បានធ្វើអន្តរាគមន៍ និងបានដាស់តឿន **ឌុច** ថា សាក្សីអាចនឹងតតាំងនឹងយថាភាពនៃឯកសារដែលដាក់នៅចំពោះមុខខ្លួន និងមិនផ្តល់មតិយោបល់ទៅលើឯកសារទាំងនេះ មុនពេលមេធាវីការពារក្តីសាកសួរសំណួរគាត់ (ជាបឋម សាក្សីអាចនឹងផ្តល់ការយល់ឃើញរបស់ខ្លួន ថាតើខ្លួនធ្លាប់បានឃើញ ឬដឹងអ្វីខ្លះពីឯកសារនេះ)។ ទោះជាយ៉ាងនេះក្តី មេធាវី **ផេស្គមិន** បានតវ៉ាថា នេះជាតួនាទីរបស់ភាគីនៅក្នុងសំណុំរឿងក្នុងការតទល់លើបញ្ហាយថាភាពនៃឯកសារ មិនមែនជាតួនាទីរបស់សាក្សីនោះទេ។

នៅពេលចាប់ផ្តើមដំណើរការសវនាការនៅពេលរសៀល អង្គជំនុំជម្រះបានសម្រេចពីការទទួលយកឯកសារនៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ដោយថ្លែងថា ឯកសារដែលទទួលស្គាល់ថាជាសំណុំភស្តុតាង (ឯកសារទាំងនេះត្រូវមានលេខយោងនៅក្នុងដីកាដំណោះស្រាយ) ដូច្នេះ តុលាការនឹងវាយតម្លៃពីទម្ងន់នៃភស្តុតាងនៅដំណាក់កាលចុងក្រោយ។

## ច.	តុល្យភាពនៃសិទ្ធិ

នៅថ្ងៃទីបីនៃសវនាការសប្តាហ៍នេះ មេធាវី **ផេស្គមិន** បានស្នើអង្គជំនុំជម្រះអនុញ្ញាតឲ្យកូនក្តីខ្លួន **នួន ជា** ប្រើពេលវេលា ៥នាទី ដើម្បីធ្វើសេចក្តីថ្លែងការណ៍តបនឹងសក្ខីកម្មរបស់សាក្សី **ឌុច** ។ ភាគីសហព្រះរាជអាជ្ញាមិនបានជំទាស់នឹងការស្នើសុំនេះទេ តែបានចង្អុលបង្ហាញថា **នួន ជា** ក៏ត្រូវតែឆ្លើយសំណួរនៅពេលភាគីដទៃមានបំណងចង់សួរគាត់ បន្ទាប់ពីគាត់បញ្ចប់សេចក្តីថ្លែងការណ៍របស់ខ្លួន។ ភាគីសហព្រះរាជអាជ្ញាក៏បានស្នើទៅអង្គជំនុំជម្រះឲ្យផ្តល់តម្លៃទៅលើសេចក្តីថ្លែងការណ៍របស់ **នួន ជា** ប្រសិនបើជនជាប់ចោទបន្តបដិសេធនៅស្ងៀមមិនឆ្លើយសំណួរ។ ចំណែកឯ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី **បាណាបេ ណេគ្រី** បានផ្តល់យោបល់ថាសេចក្តីថ្លែងការណ៍របស់ **នួន ជា** គួរតែត្រូវបានចាត់ទុកថាជាសក្ខីកម្មមួយ មានន័យថា ភាគីទាំងឡាយគួរត្រូវ

បានអនុញ្ញាតឲ្យសួរដេញដោលគាត់ ផ្អែកលើសេចក្តីថ្លែងការណ៍នេះ។ លើសពីនេះ លោកមេធាវីបានអំពាវនាវពីសេចក្តីត្រូវការចាំបាច់ ដែលអង្គជំនុំជម្រះសាលាដំបូងគួរធ្វើការថ្លឹងថ្លែងរវាងសិទ្ធិរបស់ជនជាប់ចោទក្នុងការនៅស្ងៀមមិនឆ្លើយសំណួរ ជាមួយនឹងសិទ្ធិរបស់ភាគីដទៃទៀត អនុលោមតាមគោលការណ៍មូលដ្ឋានគ្រឹះនៃការទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ ដូចមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ។ លោកមេធាវីបន្ថែមថា ពុំមានវិធានណាមួយដែលអនុញ្ញាតឲ្យជនជាប់ចោទ *"អាចធ្វើសេចក្តីថ្លែងការណ៍ ក្នុងអំឡុងពេលដែលខ្លួនបានអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយសំណួរ"*។ អង្គជំនុំជម្រះ មិនបានធ្វើសេចក្តីថ្លែងការណ៍តបចំពោះការលើកឡើងរបស់ភាគីសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីឡើយ ប៉ុន្តែបានលើកឡើងពីសេចក្តីសម្រេចរបស់ខ្លួនថា ខណៈនេះគឺមិនមែនជាពេលវេលាសមស្របសម្រាប់ **នួន ជា** ក្នុងការផ្តល់សេចក្តីថ្លែងការណ៍ទេ ប៉ុន្តែជនជាប់ចោទអាចធ្វើបាននៅពេលក្រោយ។

## ជំពូកទី៤៖ ការគ្រប់គ្រងសវនាការ

ដំណើរការនីតិវិធីនាសប្តាហ៍នេះ បានពើបប្រទះនឹងបញ្ហាថ្មីៗជាច្រើន ដែលជាបញ្ហាចោទក្នុងការគ្រប់គ្រងសវនាការ។ បញ្ហាចម្បងធំជាងគេ គឺឧបសគ្គនៃការគ្រប់គ្រងពេលវេលា។ ទីមួយ ការផ្តល់ពេលវេលាគ្រប់គ្រាន់ គឺជាករណីចាំបាច់សម្រាប់ភាគីក្នុងការសួរដេញដោលលើសាក្សី **ឌុច** ។ ទីពីរ ភាគីនីមួយៗ ត្រូវការឱកាសក្នុងការជជែកតវ៉ាពីគោលជំហររបស់ខ្លួនចំពោះបញ្ហាច្បាប់ និងនីតិវិធី ដែលបានកើតឡើងក្នុងដំណើរការសវនាការ។ ទីបី អង្គជំនុំជម្រះក៏ត្រូវការពេលវេលាក្នុងការពិភាក្សាលើបញ្ហានានា មុននឹងចេញសេចក្តីសម្រេច ដើម្បីឲ្យដំណោះស្រាយខ្លួនសមស្រប និងច្បាស់លាស់ដល់ភាគី។

### ក. កាលវិភាគរបស់តុលាការ

អង្គជំនុំជម្រះបានកែប្រែកាលវិភាគ ក្នុងគោលបំណងដើម្បីធានាការទទួលបានពេលវេលាស្មើគ្នារវាងភាគីទាំងអស់ និងដើម្បីឆ្លើយតបទៅនឹងភាពចាំបាច់ផ្សេងៗនៅក្នុងពេលជំនុំជម្រះក្តី។

បញ្ហាការកកស្ទះចរាចរណ៍ ដោយសារតែកិច្ចប្រជុំអាស៊ាននៅរាជធានីភ្នំពេញ បាននាំឲ្យមានការពន្យារពេលការចាប់ផ្តើមនីតិវិធីសវនាការនៅថ្ងៃច័ន្ទ។ បន្ទាប់ពីសម្រាកទទួលទានអាហារថ្ងៃត្រង់ មេធាវី **លីម៉ាង្វៀន** ដែលជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំអង្គជំនុំជម្រះឲ្យធ្វើការបញ្ជាក់ ថាតើក្រុមមេធាវីខ្លួននៅសល់ពេលវេលាប៉ុណ្ណា ក្នុងការសួរដេញដោលសាក្សី **ឌុច** ហើយលោកស្រីមេធាវីក៏បានស្នើសុំពេលវេលាបន្ថែមផងដែរ ដោយហេតុផលនៃការចាប់ផ្តើមសវនាការយឺត។ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធមិនផ្តល់ពេលវេលាបន្ថែមដល់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ក៏ប៉ុន្តែជាក់ស្តែង ការជជែកពិភាក្សាតវ៉ាលើបញ្ហានេះ គឺប្រើពេលវេលាស្ទើរតែពេញមួយរសៀល ដែលជាពេលវេលារបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ដោយហេតុនេះ អង្គជំនុំជម្រះសម្រេចបន្ថែមពេលវេលាមួយវគ្គចុងក្រោយដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីទូទាត់ចំពោះការចាប់ផ្តើមសវនាការយឺតយ៉ាវ និងថែមពេលមួយម៉ោងទៀតនៅថ្ងៃបន្ទាប់ ដើម្បីសងលើការខាតបង់ក្នុងការជជែកពិភាក្សាស្តីពីបញ្ហាកាលវិភាគ។

ជាការឆ្លើយតបនឹងសំណួររបស់មេធាវី **ផេស្តមិន** ទាក់ទងនឹងបញ្ហាកាលវិភាគពេលវេលាផ្តល់ដល់ក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះបានគូសបញ្ជាក់ថា ក្រុមមេធាវីការពារក្តីទាំងអស់នឹងមានពេលវេលាចំនួន

បីថ្ងៃ។ ក្រុមមេធាវីការពារក្តីនីមួយៗបានសម្តែងយោបល់ថា ពួកគេត្រូវការពេលវេលាបន្ថែមសម្រាប់សួរដេញដោលសាក្សី **ឌុច**។ មេធាវី **ផេស្គមិន** បានចង្អុលបង្ហាញថា ដោយសារតែភាគីសហព្រះរាជអាជ្ញា និងភាគីដើមបណ្តឹងរដ្ឋប្បវេណី ទទួលបានប្រាំពីរថ្ងៃក្នុងការសួរដេញដោលសាក្សី ដូច្នេះ ភាគីការពារក្តីក៏គួរតែត្រូវទទួលបានពេលចំនួនប្រាំពីរថ្ងៃដូចគ្នា។ អង្គជំនុំជម្រះមិនបានធ្វើសេចក្តីសម្រេចទៅលើបញ្ហានេះទេ ប៉ុន្តែបានអនុញ្ញាតឲ្យមេធាវីការពារក្តីឲ្យជនជាប់ចោទ **នួន ជា** ធ្វើការសួរដេញដោលសាក្សី **ឌុច** ចំនួនពីរថ្ងៃ និងផ្តល់ពេលវេលាបន្ថែម បន្ទាប់ពីមេធាវី **ផេស្គមិន** បានចង្អុលបង្ហាញថា ពេលវេលាដែលក្រុមខ្លួនត្រូវធ្វើការសួរតតាំងទៅលើសាក្សីរូបនេះ គឺមិនទាន់គ្រប់គ្រាន់។ ទោះបីជាទទួលពេលវេលាបន្ថែមក៏ដោយ ក៏មេធាវីជាតិ **សុន អរុណ** មិនអាចបញ្ចប់ការសួរដេញដោលសាក្សីកាលពីថ្ងៃព្រហស្បតិ៍ និងបានស្នើសុំពេលវេលាបន្ថែមមួយម៉ោងទៀត។ មុនសម្រេចលើសំណើសុំនេះ អង្គជំនុំជម្រះបានចោទសួរទៅក្រុមមេធាវីការពារក្តីផ្សេងទៀត អំពីពេលវេលាដែលពួកគេត្រូវប្រើប្រាស់ចំពោះសាក្សី។ មេធាវី **កាណាវ៉ាស** និងមេធាវី **វែគេន** បានស្នើសុំពេលវេលាមួយថ្ងៃពេញសម្រាប់ក្រុមនីមួយៗ។ ដោយសារសវនាការសប្តាហ៍ក្រោយមានរយៈពេលតែពីរថ្ងៃ (ឈប់សម្រាកថ្ងៃបុណ្យជាតិ) អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចថា មេធាវីការពារក្តីទាំងពីរក្រុមនឹងត្រូវចាប់ផ្តើមការសួរដេញដោលរបស់ខ្លួននៅថ្ងៃច័ន្ទ និងថ្ងៃអង្គារ។ អង្គជំនុំជម្រះ បានចង្អុលបង្ហាញថា មេធាវី **សុន អរុណ** អាចនឹងប្រើប្រាស់ពេលវេលាដែលនៅសេសសល់របស់មេធាវីទាំងពីរក្រុម ប្រសិនបើពួកគេមិនប្រើប្រាស់អស់នោះទេ។

### ខ. ឥរិយាបថនៅក្នុងបន្ទប់សវនាការ

ឥរិយាបថនៃការជជែកតតាំងដែលកើតមាននៅក្នុងបន្ទប់សវនាការនាសប្តាហ៍នេះ បានធ្វើឲ្យមានការព្រួយបារម្ភអំពីបញ្ហាសុជីវធម៌រវាងភាគីនិងភាគី។ នៅក្នុងអំឡុងពេលនៃការជជែកពិភាក្សាយ៉ាងក្តៅគគុកលើវិសាលភាពនៃភស្តុតាង ដែលអង្គជំនុំជម្រះនឹងពិចារណានៅក្នុងការធ្វើសេចក្តីសម្រេចផ្សេងៗចំពោះសំណុំរឿងនេះ លោកមេធាវី **កាណាវ៉ាស** បានព្យាយាមក្រោកឈរបញ្ចេញមតិយោបល់ជាច្រើនលើក ដែលធ្វើឲ្យអង្គជំនុំជម្រះចាត់ទុកថា ជាទង្វើមិនគោរពដល់អង្គជំនុំជម្រះ។ ប្រធានអង្គជំនុំជម្រះ **និល ណុន** បានប្រតិកម្មថា *"យើងអត់ទាន់ឲ្យនិយាយផង អត់ទាន់សុំយើងផង"*។ ប្រធានអង្គជំនុំជម្រះបានផ្តល់ដំបូន្មានថា មេធាវីត្រូវស្នើសុំអង្គជំនុំជម្រះជាមុន មុនឡើងថ្លែងបញ្ហាណាមួយ។ ប្រធានអង្គជំនុំជម្រះបានថ្លែងបន្តថា *"ឥឡូវលោកកំពុងតែសុំនិយាយ ឬក៏លោកចុចក្បាលមេក្រូនិយាយអីចឹង? ព្រោះលោកបានសន្យារួចហើយថា មុននឹងនិយាយ គឺសុំអនុញ្ញាតពីយើង"*។[25]

ការសម្តែងអាកប្បកិរិយាមិនសមរម្យនៅក្នុងការពិភាក្សាដេញដោលត្រូវបានផុសឡើង ជាជាក់ស្តែងភាពតានតឹងក្នុងការធ្វើទំនាក់ទំនងរវាងសាក្សី **ឌុច** និង មេធាវី **ផេស្គមិន** ។ **ឌុច** បានបដិសេធមិនព្រមឆ្លើយតបសំណួររបស់មេធាវី **ផេស្គមិន** ជាច្រើន។ មេធាវី **ផេស្គមិន** ក៏បានប្រើពាក្យធ្ងន់ៗ ដូចជា *"កុហក"* និង *"មិនទៀងត្រង់"* ជាដើម នៅពេលឆ្លើយបកទៅសាក្សី និងនៅពេលតាំងសំណួរដល់សាក្សី។ នេះមិនមែនជាទង្វើដែលបង្ហាញពីមន្ទិលសង្ស័យលើភាពជឿជាក់របស់សាក្សីទេ វាក៏បានបង្ហាញពីភាពរឹងត្អឹងរបស់មេធាវី ដែលនាំឲ្យសាក្សីខឹងសម្បារផងដែរ។[26] អង្គជំនុំជម្រះសាលាដំបូងបានធ្វើការណែនាំមេធាវី និងបង្គាប់មិនឲ្យសាក្សីឆ្លើយសំណួរ ដោយហេតុការប្រើប្រាស់ពាក្យសម្តីថា *"ជាមនុស្សមិនទៀងត្រង់"* ដែលជា *"ការដាក់សម្ពាធ និងប្រមាថដល់សាក្សី"* ។ មេធាវី **ផេស្គមិន** បានឆ្លើយតបថា គាត់មិនមែនជាមនុស្សទីមួយ ដែលប្រើពាក្យ

*"កុហក"* និង *"មិនទៀងត្រង់"* ទេ គាត់បានកត់សម្គាល់ថា **ឌុច** ខ្លួនគាត់ផ្ទាល់ក៏ប្រើប្រាស់ពាក្យ *"មិនទៀងត្រង់"* ចំពោះមេធាវីនៅក្នុងពេលជជែកពិភាក្សាកន្លងមក។ លើសពីនេះ មេធាវី **កាណាវ៉ាស** បានចង្អុលបង្ហាញថា នៅក្នុង *"សវនាការបើកការចោទប្រកាន់"* សហព្រះរាជអាជ្ញាបានហៅជនជាប់ចោទថាជា *"ឃាតករ"* ប៉ុន្តែមិនមានប្រតិកម្ម ឬអន្តរាគមន៍ពីសំណាក់អង្គជំនុំជម្រះឡើយ ដែលនេះជាការប្រើប្រាស់ពាក្យសម្តីមិនសមរម្យទាល់តែសោះ។ មេធាវីបានបន្ថែមថា ភាគីគួរតែអាចប្រឈមតតាំងជាមួយសាក្សី ដើម្បីឆ្លុះឲ្យឃើញនូវភាពមិនស្មោះត្រង់។ បន្ទាប់ពីបញ្ចប់ការពិភាក្សានេះ អង្គជំនុំជម្រះមិនបានចេញសេចក្តីសម្រេចលើបញ្ហានេះទេ ប៉ុន្តែបានចង្អុលបង្ហាញថា អង្គជំនុំជម្រះនៅតែរក្សាសេចក្តីសម្រេចដំបូងរបស់ខ្លួន ពោលគឺមិនឲ្យសាក្សីឆ្លើយសំណួរ។

### គ. វត្តមាន

មុនចាប់ផ្តើមសវនាការថ្ងៃព្រហស្បតិ៍ ប្រធានអង្គជំនុំជម្រះបានប្រកាសថា ចៅក្រម ***ហ្សង់ម៉ាក ឡាវែន៍*** មិនអាចចូលរួមដំណើរការនីតិវិធីបានទេ ដោយសារតែបញ្ហាសុខភាព។ ដូច្នេះ ចៅក្រមបម្រុង ***ក្លូឌៀរ ហ្វិនស៍*** បានចូលជំនួសចៅក្រម ***ឡានវែន៍*** ជាបណ្តោះអាសន្ន។

នាសប្តាហ៍នេះ ជនជាប់ចោទទាំងបីមានវត្តមាននៅពេលព្រឹកទាំងបួនថ្ងៃ លើកលែងតែជនជាប់ចោទ **ខៀវ សំផន** ដែលមានវត្តមាននៅក្នុងបន្ទប់សវនាការនៅគ្រប់កិច្ចដំណើរការនីតិវិធី។ ដូចសព្វមួយដង នៅចុងបញ្ចប់នៃវគ្គសវនាការទីមួយ មេធាវី **អាង ឧត្តម** បានស្នើសុំឲ្យ **អៀង សារី** ទៅតាមដានកិច្ចដំណើរការនីតិវិធីពីចម្ងាយ ពីបន្ទប់សោតទស្សន៍ ដោយសារតែជម្ងឺខ្នង និងចង្កេះរបស់ជនជាប់ចោទ។ មុនសម្រាកអាហារថ្ងៃត្រង់ តាមរយៈមេធាវីអន្តរជាតិរបស់ខ្លួន **នួន ជា** ក៏ស្នើសុំទៅតាមដានពីចម្ងាយផងដែរ។ ចំណែកឯមេធាវីការពារក្តីជាតិ និងអន្តរជាតិ ទាំងបីក្រុមមានវត្តមាននៅក្នុងបន្ទប់សវនាការ។

**វត្តមានរបស់សាធារណជន ៖** សប្តាហ៍នេះ ចាប់ពីវគ្គដំបូងដល់វគ្គទីបីនៃសវនាការ តែងតែមានការចូលរួមយ៉ាងច្រើនកុះករពីសាធារណជននៅក្នុងសាលសវនាការ ប៉ុន្តែចំនួននេះថយចុះមកវិញនៅក្នុងវគ្គទីបួន (វគ្គចុងក្រោយនៃសវនាការ) ដោយសារទស្សនិកជនភាគច្រើនធ្វើដំណើរត្រឡប់ទៅភូមិឋានរបស់ខ្លួនវិញ។ វត្តមានរបស់សាធារណជន ប្រមាណជា ៤០០នាក់ រួមមាន សិស្សានុសិស្សមកពីវិទ្យាល័យភ្នំជីសូរ សិស្សានុសិស្សមកពីវិទ្យាល័យស្វាយរៀង ក៏ដូចជា សិស្សានុសិស្សមកពីវិទ្យាល័យ ព្រមទាំង អ្នកភូមិមកពីខេត្តតាកែវ ក៏បានចូលរួមផងដែរ។ ក្រៅពីនេះ ដើមបណ្តឹងរដ្ឋប្បវេណីជាង ២០រូប ក៏មានវត្តមាននៅសាលសវនាការ និងបន្ទប់សវនាការ។

## ឃ. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | ផ្អាកសវនាការ | រយៈពេលសវនាការសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ០២/០៤/១២ | ៩:៣១ | ១០:៣៩-១១:០០ | ១២:០០-១៣:៣៣ | ១៤:៥៦-១៥:១៤ | ១៦:១៩ | ៤ម៉និង ៣៦នាទី |
| ថ្ងៃអង្គារ ០៣/០៤/១២ | ៩:០៨ | ១០:៣៤-១១:១៦ | ១២:០៤-១៣:៣៧ | ១៤:៣១-១៤:៥៤ | ១៦:០១ | ៤ម៉និង ១៥នាទី |
| ថ្ងៃពុធ ០៤/០៤/១២ | ៩:០៦ | ១០:៣៦-១១:០១ | ១២:០២-១៣:៣៨ | ១៤:៤៨-១៥:០៩ | ១៦:០០ | ៤ម៉និង ៣២នាទី |
| ថ្ងៃព្រហស្បតិ៍ ០៥/០៤/១២ | ៩:០៥ | ១០:៥៥-១១:២០ | ១២:១៤-១៣:៣៣ | ១៤:៣៧-១៥:០០ | ១៦:១២ | ៥ម៉និង ០០នាទី |
| *រយៈពេលសវនាការជាមធ្យម* | | | | *៤ម៉ោង និង៣៦នាទី* | | |
| *រយៈពេលសវនាការសរុបក្នុងសប្តាហ៍នេះ* | | | | *១៨ ម៉ោង និង២៣នាទី* | | |
| *ចំនួនម៉ោង ថ្ងៃ និង សប្តាហ៍នៃសវនាការ* | | | | *២០៥ម៉ោង និង៥៥នាទី* | | |
| *រយៈពេលសវនាការចំនួន ៤៧ ថ្ងៃ អំឡុងពេល ១៣ សប្តាហ៍* | | | | | | |

---

* This issue of KRT Trial Monitor was authored by Mary Kristerie A. Baleva, Nora Fuchs, Vidjia Phun, Princess B. Principe, Noyel Ry and Penelope Van Tuyl as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT Trial Monitor reports on Case 002 are available at <www.krtmonitor.org>, <http://forum.eastwestcenter.org/Khmer-Rouge-Trials/> and <http://socrates.berkeley.edu/~warcrime/>. AIJI is a collaborative project between the East-West Center, in Honolulu, and the University of California, Berkeley War Crimes Studies Center. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

[1] The OCP requested for additional time for the third time during last week's proceedings. Following objections from the Defense Teams, the Civil Party lawyers offered one hour of their allotted time to examine Duch to the OCP. The Trial Chamber denied the OCP's request but allowed them to use the additional hour from the Civil parties. See KRT Trial Monitor Issue No. 16, Week 11 of the Hearing on Evidence (26-29 March 2012).

[2] In contrast, Nuon Chea described the contradiction between peasants and landowners as an "internal contradiction" that may be resolved through study sessions, discussions and other procedures. For more information on Nuon Chea's testimony on contradictions, please refer to Asian International Justice Initiative. KRT TRIAL MONITOR [hereinafter CASE 002 KRT TRIAL MONITOR]. Issue No. 8, Hearing on Evidence Week 3 (10-12 January 2012).

[3] Ibid. at lines 14-15. 100.

[4] The two other members of the Standing Committee, So Phim, Secretary of the East Zone and Ung Choeun alias "Mok," Secretary of Southwest Zone, worked outside of Phnom Penh.

[5] Trial Chamber. Transcript of Hearing (28 March 2012). Line 3, 50; lines 4-5. 98.

[6] Ibid. at lines 16-18. 99.

[7] Ibid. at lines 25; 1. 98-99.

[8] According to Duch, he and Seua Vasi were contemporaries.

[9] Duch identified Doeun as the Chairman of Political Office 870, later State Commerce Department. See Case 002 KRT TRIAL MONITOR. Issue No. 16, Hearing on Evidence Week 11 (26-29 March 2012).

[10] See Kamm, Henry. Cambodia: Report from a Stricken Land. New York: Arcade Publishing (1998). 145.

[11] Mr. Ouk Ket was an engineer and diplomat, as well as Third Secretary at the Cambodian Embassy in Senegal. In 1977, he was recalled by the Foreign Ministry of Cambodia and instructed to return to Phnom Penh. He was arrested and sent to Toul Sleng, where he was executed on 9 December 1977. His wife, Martine Lefeuvre and their daughter, Ouk Neary, were Civil Parties in Case 001. See Case 001. Trial Chamber. Transcript of Proceedings (17 August 2009). E1/63.1. Lines 22-25; 1-6. 14-15. See also, Case 001. Trial Chamber. "Judgement" (26 July 2010). E188. Para. 650. 233.

[12] In its Judgment in Case 001, the Trial Chamber recognized Ms. Ros Chuor Siy Mr. Ros Sarin as a Civil Party for the loss of her husband Ros Sarin. See Case 001. Trial Chamber. "Judgement" (26 July 2010). E188. Para. 650. 231.

[13] It is interesting to note that Comrade Toeung, mentioned here by Duch, was called next to testify before the Trial Chamber and corroborated Duch's testimony that he served as a messenger between the S-21 Chief and Nuon Chea. See Case 002 KRT TRIAL MONITOR. Issue No. 19, Hearing on Evidence Week 14 (18-20 April 2012).

[14] According to Duch, Pang's real name is Chhim Sam Aok. Duch identified Pang as the head of the Government Office. See Case 002 KRT TRIAL MONITOR. Issue No. 16, Hearing on Evidence Week 11 (26-29 March 2012). 4.

[15] See Rithy Panh, Director. S-21: The Khmer Rouge Killing Machine (2007).

[16] Mr. Heng Samrin has been the President of the National Assembly of Cambodia since 2006.

[17] Later, Mr. Peschoux served as the Representative of the UN High Commissioner for Human Rights in Cambodia for four years.

[18] Mohamed Faizal Mohamed Abdul Kadir. The Rule in Browne v. Dunn in Cross Examination: A Singapore Perspective. www.lawgazette.com.sg/2011-07/155.htm.

[19] Browne v. Dunn. 6 R. 67. H.L. (01 January 1894) provides in part:

> …it seems to me to be absolutely essential to the proper conduct of a cause, where it is intended to suggest that a witness is not speaking the truth on a particular point, to direct his attention to the fact by some questions put in cross-examination showing that the imputation is intended to be made, and not to take his evidence and pass it by as a matter altogether unchallenged, and then, when it is impossible for him to explain, as perhaps he might have been able to do if such questions have been put to him, the circumstances which it is suggested indicate that the story he tells ought not to be believed, to argue that he is a witness unworthy of credit. My Lords, I have always understood that if you intend toimpeach a witness you are bound, whilst he is still in the box, to give him an opportunity of making any explanation which is open to him.

[20] Each page of documentary evidence in the Case File has a unique ERN.

[21] See Rithy Panh, Director. Duch, Master of the Forges of Hell (2011).

[22] Case 001. Trial Chamber. "Judgement" (26 July 2010). 170. 62.

[23] Trial Chamber. "Memorandum, ( Updated Memorandum for next document hearing (12-19 March 2012))" (2 March 2012). E172/5. para. 4. 2.

[24] According to Duch, he was rejecting the interview on the following grounds: (i) it was not given to him in the original form; (ii) the date of the document was different from the date of the interview with Mr. Peschoux; (iii) it contained some inconsistencies, (iv) there were alleged inaccuracies in the tape of the interview.

[25] See CASE 002 KRT TRIAL MONITOR. Issue No. 16, Hearing on Evidence Week 11 (26-29 March 2012). 13.

[26] On Wednesday morning, Pestman asked Duch: "I put it to you that the dishonest person is not me but is you. Why did you lie to Investigating Judges?" on his knowledge of the three terms used in S-21 "hot group, cold group and chewing group." On Thursday, he confronted Duch: "I put to you that you are dishonest and that you are blaming Nuon Chea for crimes you committed."